មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ អែម អៀន អាយុ៥២ឆ្នាំ ភេទស្រី

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**មុខងារសម័យខ្មែរក្រហមៈ ធ្វើការនៅចំការកៅស៊ូ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៣៣:៤៦**

**៣៨ទំព័រ**

ដានីៈ មីងដំបូងចង់ស្គាល់ឈ្មោះមីង ឈ្មោះមីងពេញឈ្មោះអីទៅ?

អៀនៈ ឈ្មោះ អែម អៀន ។

ដានីៈ “អ” ដាក់ស្រៈ “ែ” និង“ម” ឬស្រៈពេញតួ?

អៀនៈ “អ”ស្រៈ “ែ” និង“ម” ។

ដានីៈ អែម អៀន?

អៀនៈ ចា៎!

ដានីៈ មីងអាយុហើយសព្វថ្ងៃ?

អៀនៈ អាយុ៥២ ។

ដានីៈ មីងកំណើតកើតជានៅភូមិ-ឃុំ ស្រុកអីដែរ?

អៀនៈ កំណើតកើតជានៅភូមិទំនប់ ។

ដានីៈ ឃុំអីដែរហ្នឹង?

អៀនៈ ឃុំស្រើង ។

ដានីៈ ស្រុកអីនោះ?

អៀនៈ ស្រុកគេប្រែប្រាសាទសំបូរ តែពីដើមស្រុកសន្ទុក តែឥឡូវគេប្រែប្រាសាទសំបូរហើយ ។

ដានីៈ នៅម្តុំណាទៅហ្នឹងភូមិមីង?

អៀនៈ នៅមួយផ្លូវខាងលើកំពង់ធំ ។

ដានីៈ ពីកំពង់ស្វាយទៅមានផ្លូវមួយទៅព្រះវិហារ?

អៀនៈ ហ្នឹងហើយ ។

ដានីៈ កាលមុនស្រុកសន្ទុកវានៅខាងក្រោមវិញ?

អៀនៈ ចា៎!

ដានីៈ គេដាក់ស្រុកសំបូរពីអង្កាល់?

អៀង៖ គេដាក់ស្រុកប្រាសាទសំបូរ មើលគេដាក់ស្រុកប្រាសាទសំបូរនេះឆ្នាំ៨២-៨៣ហើយ ។

ដានី៖ ប្រធានភូមិត្រូវជាគ្រួសារមីង?

អៀង៖ ចា៎!

ដានី៖ គាត់ឈ្មោះ?

អៀង៖ ញ៉ឹក អ៊ិន នៅភូមិជាមួយគ្នាហ្នឹង ។

ដានី៖ ស្រុកកំណើតនៅភូមិជាមួយគ្នា?

អៀង៖ ចា៎!

ដានី៖ គាត់អាយុប៉ុន្មានដែល? បងមីងឬប្អូនមីង?

អៀង៖ ខ្ញុំប្អូនគាត់ទេ ។

ដានី៖ ប្អូនគាត់ប៉ុន្មានឆ្នាំ?

អៀង៖ ប្អូនគាត់៥ឆ្នាំ ។

ដានី៖ អីចឹងគាត់អាយុ៥៧ហើយ?

អៀង៖ ចា៎!

ដានី៖ គាត់អ្នកស្រុកកំណើតជាមួយគ្នា? នៅភូមិទំនប់ជាមួយគ្នា?

អៀង៖ ចា៎!

ដានី៖ ហើយមីងមានកូនចៅប៉ុន្មាននាក់?

អៀង៖ អត់មានទេ ។

ដានី៖ ការជាមួយគាត់តាំងពីឆ្នាំណា?

អៀង៖ ការតាំងពី៨២ ។ ៧៩មក៨០, ៨១-៨២បានការ ។

ដានី៖ មីងឪពុកមីងគាត់ឈ្មោះអីទៅ?

អៀង៖ ឈ្មោះ សំ តែត្រកូលគាត់ ជីតាគាត់មិនដឹងឈ្មោះអីទេ ខ្ញុំដឹងត្រឹមតាខ្ញុំ អែម សំ ។

ដានី៖ សព្វថ្ងៃគាត់នៅរស់ ឬខូចហើយ?

អៀង៖ គាត់ស្លាប់ហើយ នៅតែម្តាយទេ ។

ដានី៖ ម្តាយហ្នឹងឈ្មោះអីទៅ?

អៀង៖ ម្តាយឈ្មោះ ឃឹម ដួន ។

ដានី៖ បងប្អូនប៉ុន្មាននាក់ដែរ?

អៀង៖ គិតតែរស់?

ដានី៖ ទាំងអស់តែម្តង?

អៀង៖ ទាំងអស់១២នាក់ ។

ដានី៖ ច្រើនដែល?

អៀង៖ ចាំ!

ដានី៖ ១២នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អៀង៖ ប្រុស៣ ស្រី៨ ។ ១២នាក់ ។

ដានី៖ ១២នាក់ ប្រុស៣នាក់ ស្រី៨ ទាំងអស់៩ទាំងមីង?

អៀង៖ ចាំ!

ដានី៖ ចុះម្ដាយមីងសព្វថ្ងៃគាត់នៅរស់ គាត់នៅណា?

អៀង៖ នៅស្រុក នៅភូមិទំនប់ ។

ដានី៖ បងប្អូនមកនៅជាមួយមីងប៉ុន្មាននាក់ដែរ?

អៀង៖ បងប្អូនខ្ញុំមកនៅនេះ នៅ៥នាក់នៅអូរឫស្សីនោះមួយ ។

ដានី៖ នៅស្រុកប៉ុន្មាននាក់?

អៀង៖ នៅស្រុកគិតទាំងអ្នកស្លាប់ឬអត់ទេ គិតអ្នកនៅរស់?

ដានី៖ នៅរស់ប៉ុន្មាននាក់?

អៀង៖ អ្នករស់៣ នៅ៣នាក់ ។

ដានី៖ ស្លាប់អស់ប៉ុន្មាននាក់?

អៀង៖ ស្លាប់អស់៣ ស្រី១ ប្រុស២ ។

ដានី៖ ម្ដាយគាត់?

អៀង៖ ស្រី២ លោកគ្រូស្រី២ ។

ដានី៖ ស្លាប់អស់ប៉ុន្មាននាក់អីចឹង?

អៀង៖ ស្លាប់អស់៤ ស្រី២ ប្រុស២ ។

ដានី៖ អីចឹងនៅសល់តែ៣នាក់ទេ នៅស្រុក ។

អៀង៖ នៅ៣ ។

ដានី៖ អីចឹងនៅនេះ៥នាក់?

អៀង៖ ៥ ។

ដានី៖ ហើយម្ដាយមីងគាត់ធ្លាប់មកលេងនេះអត់?

អៀង៖ គាត់ធ្លាប់មក មកលេង ។

ដានី៖ គាត់មកលេងបានយូរៗទេ?

អៀង: បានយូរ ១-២ខែបានអញ្ជើញទៅវិញ ។

ដានី: គាត់នៅមាំដែរ?

អៀង: ឥឡូវរាងអន់ហើយ គាត់យាប់ជង្គង់ ។

ដានី: អាយុប៉ុន្មានហើយ?

អៀង: ចូលហុកជាងហើយដឹង ខ្ញុំអត់ចាំគាត់ ហុកជាងហើយ ៦៥-៦៦ ។

ដានី: មីង៥២ហើយគាត់?

អៀង: ខ្ញុំបងគេ ជំបូងគេ ។

ដានី: មីងបងគេបង្អស់?

អៀង: ចា៎! ចូលហុក ចិតហើយទេដឹង ។

ដានី: មីងកូនទីប៉ុន្មាន? កូនបងទី១តែម្តង?

អៀង: ទី១ ។

ដានី: កាលពីក្មេងៗមីងបានរៀនសូត្រដល់ណាដែរ?

អៀង: អត់មានបានរៀនទេលោកគ្រូខ្ញុំ ដឹងក្តីមកគឺជាប់កងចល័តតែម្តង អត់មានបានចូលរៀនសូត្រនឹងគេទេ ។

ដានី: ហើយគេបែកចូលឆ្នាំ៧៥មក?

អៀង: ៧៥កាលខ្ញុំនៅភូមិ-ឃុំ នៅកងចល័តកុមារ ផុតពីកងចល័តកុមារទៅគេឲ្យទៅកងចល័តវែកដីនៅទំនប់១មករា ។

ដានី: ឆ្នាំណា?

អៀង: ទំនប់១មករា ឆ្នាំ ។

ដានី: ពីដំបូងបំផុតនៅកងចល័តកុមារ?

អៀង: ចា៎!

ដានី: កងចល័តកុមារនៅណា?

អៀង: កងចល័តនៅឃុំ ។

ដានី: ឃុំអីគេហ្នឹង?

អៀង: ឃុំស្រើង ។

ដានី: គេឲ្យយើងធ្វើអីខ្លះទៅហ្នឹង?

អៀង: គេឲ្យយើងវែកដី ឲ្យគាស់គល់ ឲ្យយើងប្រមូលជីអាចម៍គោ អាចម៍ក្របី ។

ដានី: ដល់ពេលផុតពីកងចល័តកុមារចូល?

អៀងៈ ផុតពីកងចល័តកុមារ គេឲ្យមកនៅកងចល័តនារី មកវែកដីនៅទំនប់១មករាយើងនេះ ។

ដានីៈ ឆ្នាំណា?

អៀងៈ ៧៦ ។

ដានីៈ ៧៦ នៅកងចល័ត?

អៀងៈ ៧៦កងចល័តដល់ពេលកងចល័តវែកដីអីចឹង គេរើសឲ្យខ្ញុំទៅនៅចំការកៅស៊ូ ។

ដានីៈ កងចល័តវែកដីនៅទំនប់?

អៀងៈ ១មករា ។

ដានីៈ ទំនប់ប៉ុន្មានមករា?

អៀងៈ ១ មករា ។

ដានីៈ ១ មករាហ្នឹងនៅម្តុំណាទៅ?

អៀងៈ នៅមួយជួរពីកំពង់ថ្មមក ទី១, ទី២, ទី៦ លើកមួយជួរហ្នឹងរហូតមក ហើយបានគេរើសកំលាំងថាឲ្យទៅកាត់ដេរ ដល់ពេលអត់បានកាត់ដេរ គេឲ្យទៅចំការកៅស៊ូកិនជ័រ ។

ដានីៈ ឆ្នាំណាហ្នឹង?

អៀងៈ ហ្នឹងឆ្នាំ៧៧-៧៨ ។

ដានីៈ ៧៧-៧៨គេរើសឲ្យទៅចំការកៅស៊ូ ធ្វើអីនៅចំការកៅស៊ូ?

អៀងៈ ចំការកៅស៊ូកិនជ័រសន្ទឹក ជ័រកៅស៊ូ ។

ដានីៈ ទៅនៅណាហ្នឹង?

អៀងៈ នៅជួរតាប្រុក ជួរថ្នល់បំបែក៣៣, ២២ហ្នឹង ។

ដានីៈ ដំបូងកាលពីឆ្នាំ៧៥ នៅកងចល័តកុមារនៅឃុំស្រើងនៅឡើយ កាលហ្នឹងយើងគាស់គល់ប្រមូលធ្វើដី កាលហ្នឹងនៅជាមួយឪពុកឬបែកចេញពី?

អៀងៈ បែក គេឲ្យមកនៅប្រមូលឲ្យនៅតាមឃុំ បែកពីម៉ែ ដូចថាភូមិអីចឹងគេប្រមូលទៅនៅទំនប់ដាច់ បែកឆ្ងាយពីម៉ែទៅ ។

ដានីៈ កាលហ្នឹងលើកដីច្រើន ហត់ ឬយ៉ាងម៉េច?

អៀងៈ ហត់មិនដឹងធ្វើម៉េចបើគេឲ្យធ្វើអីចឹងហើយ ។

ដានីៈ គ្នាច្រើនទេកាលហ្នឹង?

អៀងៈ គ្នាច្រើន មួយឃុំ មួយខេត្ត មួយស្រុក តែគេលើកតាមឃុំៗ ដូចថាឃុំស្រើង ឃុំតាំងក្រសាំង និយាយរួមមួយប្រទេសដែលគេយកទៅលើកទំនប់១ មករា ។

ដានីៈ បាទ! តែមុនទំនប់១មករា?

អៀង: មុនខ្ញុំ?

ដានី: កាលនៅឃុំ?

អៀង: នៅឃុំហ្នឹង មុន១មករា គេឲ្យដើរកាស់គល់តាមឃុំ ដូចខែកាស់គល់ៗទៅ ខែប្រាំង ខែវស្សាស្ទូងដក ដល់ពេលគេរើសឲ្យទៅ ។

ដានី: ហូបចុកគ្រប់គ្រាន់ទេកាលហ្នឹង?

អៀង: ហូបចុកលំបាកណាស់ ពេលណាគ្រប់ៗទៅ ពេលណាអត់ក៏អត់ទៅ បបរ ប៉ះណាបាយទៅ

ដានី: តែខស្សាហ៍បានមកលេងផ្ទះ?

អៀង: អត់ទេ អត់មានបានទេ ។

ដានី: អត់បានមកលេងទេ?

អៀង: អត់ដែលបានទេ បើឪពុកម្ដាយខ្ញុំនឹកខ្ញុំ ពុកខ្ញុំប៊ីសនឹងជាប់គុកដោយសារនឹកកូន កងចល័ត នៅទំនប់១មករា គាត់នឹកខ្លាំងពេក គាត់សុំប្រធានឃុំហ្នឹង ពីដើមគេហៅប្រធានសង្កាត់ គាត់អត់ថានឹកកូនទេ គាត់ថាកូនឈឺ ខ្ញុំនៅពីក្មេងត្រង់ បើអត់ដែលឈឺមែន ថាខ្ញុំអត់មាន ឈឺអីផងហ្នឹង ពុកខ្ញុំវីសគេយកដាក់គុក ឆោតល្ងង់មិនដឹងឆ្លើយថាម៉េច ។

ដានី: កាលហ្នឹងនៅក្នុងស្រុកសន្ទុកទេ?

អៀង: ចា៎! នៅស្រុកសន្ទុក ។

ដានី: អត់មានប្រាសាទសំបូរ?

អៀង: អត់មានប្រាសាទសំបូរទេ នៅស្រុកសន្ទុក ។

ដានី: កាលហ្នឹងគណៈស្រុកសន្ទុកពីណាគេ?

អៀង: គណៈស្រុកសន្ទុកសារហ្នឹងយាយលឺញ មកបានតាអីទេខ្ញុំភ្លេចទៅបាត់ហើយខ្ញុំអត់ចាំ ពីណាទេ ចាំតែឃុំ តាស្ដើង ។

ដានី: តាស្ដើង អ្នកនៅ?

អៀង: ស្ដើង អ្នកនៅតាំងក្រសាំងក្ដាប់ស្រុកខ្ញុំឃុំ ។ ក្រោយៗផ្លាស់ពីតាហ្នឹងទៀតមិនដឹងពីណា ខ្ញុំផ្លាស់ទៅបាត់ ។

ដានី: អ្នកតាកែវគេមកម្ដង?

អៀង: អ្នកតាកែវដឹង ខ្ញុំទៅបាត់ហើយអត់ដឹង ។

ដានី: ដល់ពេលអីចឹង ដល់ពេលឆ្នាំ៧៦គេជ្រើសរើសឲ្យមកកងចល័តនយុវជន-នារីម្ដង?

អៀង: កងចល័តយុទ្ធជននារីហ្នឹងគេឲ្យលើកដីទំនប់១មករា ។

ដានី: មកហ្នឹងបានយូរទេ?

អៀង៖ លើកហ្នឹងបានមួយខែ លើកបានមួយខែបានគេរើសពួកខ្ញុំហ្នឹង គេថាឲ្យទៅខាងកាត់ដេរទៅខាងពេទ្យគេរើស ដល់ពេលយើងធ្វើប្រវត្តិរូបទៅ ពួកខ្ញុំនេះគេច្រលំឈ្មោះម៉េចក៏បាននៅចំការកៅស៊ូ ។

ដានី៖ ប៉ុន្មាននាក់ទៅនៅចំការកៅស៊ូ?

អៀង៖ ចំការកៅស៊ូមួយឃុំស្រីងហ្នឹងគ្នា៧នាក់ ។

ដានី៖ ពីណាខ្លះ?

អៀង៖ នៅខ្ញុំ ភូមិខ្ញុំហ្នឹង៣នាក់ អ្នកស្រីង៣នាក់ គ្នា៧នាក់ ។

ដានី៖ អ្នកស្រីង៧នាក់?

អៀង៖ គេរើសស្រីង៧នាក់ គេរើសតាមភូមិ តាមស្រុក ។

ដានី៖ ពេលដែលគេជ្រើសរើសចេញពីហ្នឹងទៅនៅចំការកៅស៊ូ?

អៀង៖ ចា៎!

ដានី៖ នៅកន្លែងតាប្រុក?

អៀង៖ ហ្នឹងហើយ នៅកន្លែងតាប្រុក ។

ដានី៖ តាប្រុកហ្នឹងកន្លែងចំការកៅស៊ូរបស់ស្អីគេ?

អៀង៖ ចំការកៅស៊ូពីដើមនោះគេហៅបារាំង ដល់ក្រោយមកបានអង្គការ មិនដឹងគេហៅស្អីខ្ញុំអត់ស្គាល់ដែរមួយសារហ្នឹង ។

ដានី៖ គ្នាច្រើនទេអ្នកនៅចំការកៅស៊ូ?

អៀង៖ គ្នាច្រើន រាប់រយ ៥០០ទាំងអ្នកមានគ្រួសារ ទាំងលីវ ចូលពាន់នាក់ដែលហ្នឹង ។

ដានី៖ ពាន់នាក់?

អៀង៖ ចា៎! ចំការកៅស៊ូនៅជាមួយអ៊ំជីម ហ្នឹងឯង ។

ដានី៖ នៅជាមួយអ៊ំជីម?

អៀង៖ ចា៎!

ដានី៖ មន្ទីរអ៊ំជីម នៅកន្លែងណាកាលហ្នឹង?

អៀង៖ មន្ទីរអ៊ំជីម នៅមន្ទីរក្នុង ។

ដានី៖ អ៊ំជីម ឥឡូវគាត់នៅភូមិណា?

អៀង៖ នៅផ្សាវ ។

ដានី៖ នៅជិតគាត់តែម្តង?

អៀង៖ ខ្ញុំនៅដូចថាកង គាត់នៅកន្លែងមន្ទីរគេក្នុងមេធំៗ ។

ដានី៖ គាត់នៅជាមួយពីណាខ្លះ?

អៀង៖ គាត់នៅអគ្គភាពគាត់យោធាហ្នឹង ។

ដានី៖ ហ្នឹងមានអគ្គភាពយោធាដែរ? ចំការកៅស៊ូ?

អៀង៖ មាន ចំការកៅស៊ូ មាននារី យុទ្ធជន ធ្វើការរោងចក្រចំការកៅស៊ូទៅ កន្លែងមន្ទីរក្នុងៗ ចល័ត ។

ដានី៖ មីងអត់ដែលចេញចូលទេ?

អៀង៖ អត់ទេ អត់ដែលចេញចូលទេ ចេញចូលតែអ្នក ប្រជាជនដូចអស់ខ្ញុំអត់ដែលទេ បើគេពីក្នុងចូលមកន្លែងយើងមើលអីបាន តែថាយើងចូលទៅកន្លែងគេអត់បានទេ ទាល់តែគេរើស

ដានី៖ តែភាគច្រើនអ្នកដែលធ្វើការនៅហ្នឹងច្រើនតែអ្នកមកពីតាកែវ-កំពត?

អៀង៖ ចំរុះគ្នា នៅដូចថាកំពង់ធំ កំពត តាកែវ បាត់ដំបង នៅចំរុះគ្នា គេរើសកន្លែងហ្នឹង ។

ដានី៖ តែអ្នកធ្វើប្រធាន?

អៀង៖ អ្នកធ្វើប្រធានឈ្មោះ ខ្ញុំភ្លេចឈ្មោះទៅ ។

ដានី៖ ប្រធានធំជាងគេ? ប្រធានក្តាប់កន្លែងហ្នឹង?

អៀង៖ ឈ្មោះអីគេ ខ្ញុំភ្លេចបាត់ទៅហើយ ។

ដានី៖ ចុះតាជឹម ហ្នឹងគ្រាន់គាត់ប្រធានធំជាងគេ?

អៀង៖ អ៊ំជឹម គាត់នៅប្រធានខាងយោធាទេ តែពួកខ្ញុំនៅជាមួយគាត់ តាស៊ឹម ហួសពីស៊ឹម ហ្នឹងបានតាអីទេដែលក្បត់ ដល់គេចាប់តាហ្នឹងទៅបាត់បានមកនារី ខ្ញុំភ្លេចបាត់ហើយ ភ្លេចឈ្មោះយូរហើយ ភ្លេចមេក្តាប់ក្តោប ។

ដានី៖ តាកេត, តាង៉ន?

អៀង៖ ហ្នឹងហើយខ្ញុំនៅដូចថាកូនចៅគាត់ តាកេត, តាង៉ន យើងនៅតាមអគ្គភាព ក្រុម ពួក ។

ដានី៖ តាកត, តាង៉ន ឥឡូវគាត់នៅណា?

អៀង៖ អត់ដឹងទេ មិនដឹងនៅណា ។

ដានី៖ ចុះពូខាងក្រុមប្រឹក្សាស្រុករាល់ថ្ងៃ ពូសាម៉េត?

អៀង៖ ពូម៉េត?

ដានី៖ បាទ!

អៀង៖ ពូម៉េត ខ្ញុំទើបមករស់នៅ៧៩ហើយ ដែលពីដើមហៅយួនចូលៗ ពួកខ្ញុំរត់មកជួបនៅលើតែម្តង ជួបនៅលើភ្នំ ។

ដានី៖ មីងកាលនៅចំការកៅស៊ូយើងធ្វើអីខ្លះទៅ?

អៀង៖ នៅចំការកៅស៊ូឲ្យកិនដីរ ។

ដានី៖ កិនដីរ?

អៀង៖ ដីរកៅស៊ូ គេអ្នកចាក់មក យើងអ្នកបង្កក់ទៅកិនធ្វើសន្លឹក មានម៉ាស៊ីនគេបង្កក់ជាក្តារមួយតឹក ឬ៤-៥តឹក គេបង្កក់ទៅ មានម៉ាស៊ីនគេទី១, ទី២រហូតដល់ទី១០កិន ផ្នែកខ្ញុំខាងដីរសន្លឹក ។

ដានី៖ ដល់យើងបានដីរ?

អៀង៖ ដល់យើងបានដីរមានគេអ្នកចំអិនចូលក្នុងឡ ឆ្អិនមានអ្នកគេបិទធ្វើមួយដុំប៉ុណ្ណេះៗមាន៥០គីឡូ មាន៦០គីឡូ ហ្នឹងដល់ឆ្អិនគេហៅកៅស៊ូក្រែបហើយ ប៉ុណ្ណឹងឯងពួកខ្ញុំនៅកិនដីរ ។ អត់បានទៅទៅចូកចៀរអីទេ នៅកិន ម៉ោងគិតទៅយើងធ្វើពីម៉ោង៤ដល់ម៉ោង១១ ដេកបានពីម៉ោង១១ដល់ម៉ោង៤ យើងងើបទៀតទល់ម៉ោង១១ថ្ងៃទៀត ផ្លាស់គ្នា ។ ក្នុងមួយថ្ងៃផ្លាស់គ្នា២វេន មាន៣០នាក់ តាមមុខងាររោងចក្រ ។

ដានី៖ ហត់អត់មីងកាលហ្នឹង?

អៀង៖ ហត់ណាស់ តែមិនដឹងធ្វើម៉េច បើយើងផែនការគេ ។

ដានី៖ ហូបចុកគ្រប់គ្រាន់អត់?

អៀង៖ តែហូបចុកកន្លែងខ្ញុំអត់អីទេ បាយ ពេលថ្ងៃណាគេធ្វើបន្អែម មួយខែគេធ្វើឲ្យហូប១-២ដងដែរ កន្លែងខ្ញុំរឿងហូបចុកអត់សូវទេ ខ្ញុំគេឲ្យទៅនោះវិញ បើនៅកងចល័តហ្នឹងបានវេទនាហូបមិនដែលគ្រប់គ្រាន់ ។

ដានី៖ កាលនៅកងចល័ត កាលនៅលើកទំនប់១ មករាអីវេទនា?

អៀង៖ វេទនា បបរប៉ះបបរទៅ បបរគ្រាប់ពោត ពួកខ្ញុំលួចបោះយកចានហ្នឹងបោះឲ្យលិចទឹកអស់យកតែកាកទេ គ្រាប់ពោត និងអង្ករហ្នឹងនាំគ្នាហូប ខ្ញុំនៅកងចល័តយ៉ាប់ នៅតាមអគ្គភាពអត់សូវយ៉ាប់ទេ ។

ដានី៖ ដល់ពេលនៅកន្លែងអគ្គភាពដីរកៅស៊ូអត់សូវយ៉ាប់ទេ?

អៀង៖ អត់សូវយ៉ាប់ទេ ។

ដានី៖ បានមកលេងផ្ទះទេកាលហ្នឹង?

អៀង៖ អត់ទេ ទល់នឹង៧៩រត់តែម្តង ដល់រត់មកខ្ញុំរត់មកចូលផ្ទះនៅបានប្រហែល២ឆ្នាំចាស់ៗគាត់ផ្គួផ្គងគ្រួសារខ្ញុំនេះនៅ គាត់រត់មកនៅក្នុងព្រៃទេ អាមួយសារ៧៩ដល់ពេលនេះទៅគាត់រត់មកដាច់បាយ ដាច់ទឹក គ្រួសារខ្ញុំប៊ីសតែងាប់ នៅកដើងកដៃប៉ុនដងវែកទេ

ដល់នេះគាត់ចូលទៅផ្ទះ ម៉ែឪមើលថែដាទៅក៏ដណ្ដឹងការ ការបាន២ឆ្នាំគាត់មកកងវិញ គាត់ឡើងលើភ្នំ ។

ដានី: តែមីងអត់ឡើងតាមគាត់ទេ?

អៀង: ខ្ញុំអត់ទាន់ឡើងមកទេ ទល់តែឆ្នាំ៨៧បានគាត់ចុះទៅកើតទន្លេ ដល់គាត់ចុះទៅធ្វើការខាងកើតទន្លេ គេតម្រូវឲ្យឡើងភ្នំក៏គាត់យកខ្ញុំមកឡើងភ្នំឆ្នាំ៨៧-៨៨ ដល់៨៩តាម៉ុក រំដោះដីគេក៏ឲ្យប្រជាជនចុះមកនៅតាមអស់នេះឯង រហូតមក ។

ដានី: ហើយអីចឹងមីងកាលនៅកន្លែងកិនដីរកៅស៊ូបានយូរដែរ? ពី៧៧រហូតដល់៧៩?

អៀង: បាន៧៧, ៧៨, ៧៩ ។

ដានី: តែកិនដីរកៅស៊ូវែលងលំបាកហើយ ។

អៀង: អត់សូវលំបាកទេកន្លែងខ្ញុំ ម្ហូបចុកអីគ្រប់គ្រាន់ មិនយ៉ាប់ដូចនៅកងចល័ត សហករណ៍ ។

ដានី: តែយើងអត់បានទៅទស្សនៈកិច្ច ឬទៅដើរលេង?

អៀង: បាន ។

ដានី: ដើរទៅណាខ្លះ?

អៀង: ពេលសំរាកថ្ងៃអាទិត្យគេឲ្យមកទស្សនកិច្ចសៀមរាប បើមិនសៀមរាបទេគេឲ្យយើងមកមើលទំនប់១មករាហ្នឹង ។

ដានី: អីចឹងបានទស្សនកិច្ចនៅសៀមរាបដែរ?

អៀង: ចា៎! គេដឹកឡានពីដើមសុទ្ធតែឡានចិន ៣-៤ឡានទៅដណ្ដើរសៀមរាប១ថ្ងៃទៅ បានគេយកទៅចូលកន្លែងវិញ ។

ដានី: ទៅសៀមរាបមើលអី?

អៀង: មើលអង្គរ ។

ដានី: ហើយបានថតរូបទេ?

អៀង: អត់ទេ មួយសារហ្នឹងអត់មានបានថតទេ មើលមែនមើល ។

ដានី: ពីណាគេអ្នកដឹកនាំឲ្យមកមើល?

អៀង: កន្លែងភូមិចេះគេឲ្យមិត្តណាចង់ទៅណា ចង់ទៅលេងសៀមរាប ចង់ទៅលេងអីណាស្រេចតែចិត្តឲ្យតែទៅ គេដឹកឡានទៅ ។

ដានី: គេដឹកឡានទៅ?

អៀង: ទៅក្នុងមួយថ្ងៃហ្នឹងលេងទៅ ដើរមើលទៅ ។

ដានី: តាជីម ធ្លាប់បានទៅជាមួយ?

អៀង: អត់ទេ ខ្ញុំអត់ដែលបានទៅជាមួយគាត់ ។

ដានី: ក្រែងប្រពន្ធគាត់អ្នកស្រុកនៅកំពង់ចាម កំពង់ធំដែរ?

អៀង: បងប្រពន្ធក្រោយទេគាត់នៅកំពង់ធំ បើប្រពន្ធគាត់មុនដែលមួយសារខ្ញុំនៅចំការកៅស៊ូ ប្រពន្ធគាត់ដល់ពេលយួន គេហៅយួនលោកគ្រូកុំប្រកាន់ ។

ដានី: គេហៅអ៊ីចឹង ។

អៀង: គេហៅពីដើម ពេលយួនចូលប្រពន្ធគាត់ទៅនៅលិច គាត់បែកគ្នារហូត រត់គាត់ឡើងលើភ្នំ គាត់យកប្រពន្ធគាត់ទៅទុកលិចក៏បានបងរាល់ថ្ងៃ កូនគាត់ឡើងក្រមុំកំលោះអស់ហើយ ។

ដានី: ឈ្មោះ ណោន?

អៀង: ចា៎! ប្រពន្ធគាត់ឈ្មោះ ណោន ក្រោយ ។ បើកូនគាត់មុនអាណាត ស្រីៗប៉ុន្មាននាក់ ។

ដានី: កូនគាត់នៅ?

អៀង: នៅលិច នៅម៉ាឡៃ ប្រពន្ធគាត់ចំណាស់ដូចគ្នាគាត់ តែឥឡូវមកបានបងក្រោយទេក្មេង ឥឡូវបានកូន៣-៤ គាត់កំសត់កំរ គាត់យកប្រពន្ធគាត់ទៅនោះ រត់ចូលព្រៃគាត់ធ្វើទៀ

ដានី: កាលហ្នឹងចំការកៅស៊ូហ្នឹងរបស់តំបន់ ឬរបស់ភូមិភាគ?

អៀង: របស់តំបន់ ។

ដានី: របស់តំបន់ណា?

អៀង: គេហៅភូមិភាគទេដឹង ភាគកណ្ដាលៗ ។

ដានី: របស់ភូមិភាគកណ្ដាល?

អៀង: ចា៎! ភូមិភាគកណ្ដាល ។

ដានី: កាលហ្នឹងពីណាគេគណៈតំបន់កណ្ដាល ។

អៀង: ខ្ញុំភ្លេចគណៈភូមិភាគ ខ្ញុំភ្លេច ពីដើមធ្លាប់នេះឈ្មោះតាពកៗ ស្រួលមិនស្រួលគណៈភូមិភាគ ហ្នឹងតាពកហ្នឹងឯងយ៉ាង ព្រោះខ្ញុំធ្លាប់តែឃើញគេទស្សនកិច្ច ឲ្យយើងទទួលពេលគេចង់មក ទស្សនៈកិច្ច យើងចាំទទួលគេ ។

ដានី: កាលហ្នឹងចាំទទួលពីណាខ្លះតាមមីងចាំ?

អៀង: ចាំទទួលគេអ្នកធំៗគេមកមើលយើងធ្វើការក្នុងរោងចក្រ ។

ដានី: ពីណាខ្លះដែលធ្លាប់ទៅមកមើល?

អៀង: មិនចាំទេ មិនដឹងពីណាពីណី គេអ្នកធំៗគ្រាន់តែឃើញមុខគេ ។

ដានី: ឃើញតាពក ទៅ?

អៀង: ចា៎! ឃើញតាហ្នឹងឯង ។

ដានី: ចុះតាអាន គាត់ធ្លាប់ទៅទេ?

អៀង: មិនដឹងម៉េច ។

ដានី: មីងស្គាល់គាត់ដែរ?

អៀង: តាអាន?

ដានី: បាទ!

អៀង: ស្គាល់លឺតែសំលេង លឺតែឈ្មោះទេ តែមិនដែលឃើញមុខទេ បើតាពក បានខ្ញុំឃើញ ។

ដានី: តាអាន លឺតែឈ្មោះ?

អៀង: លឺតែឈ្មោះ ខ្ញុំអត់សូវបានឃើញ ។

ដានី: ចុះតាស៊ីម?

អៀង: តាស៊ីម ក៏ឃើញស្រពេចស្រពិលដែរ មួយសារហ្នឹងមិនចាប់អារម្មណ៍ប្រឹងធ្វើតែការងារ អ្នកធំ អ្នកតូចមក ។

ដានី: ចុះមីងឈ្មោះនី បងនី ស្រី?

អៀង: នី ណា?

ដានី: នៅកំពង់ធំ ។

អៀង: អត់ ។

ដានី: អត់ដែលស្គាល់?

អៀង: អត់ដែលស្គាល់ ខ្ញុំទាល់តែនៅដូចថាអង្គភាពស្រុកភូមិបានស្គាល់គ្នា ទាំងអស់គ្នា ធ្វើការ អង្គភាពឆ្ងាយៗពីគ្នាអត់សូវស្គាល់ដែរ ពេលជួបគ្នាម្តងៗ ពេលមេទ្ទិញជួបគ្នាម្តងៗ ។

ដានី: ពេលមេទ្ទិញ?

អៀង: ចា៎! មេទ្ទិញរាប់រយ រាប់ពាន់នាក់ ។

ដានី: ពេលមេទ្ទិញច្រើនមេទ្ទិញនៅណា?

អៀង: មេទ្ទិញនៅកន្លែង ធ្វើក្រោមដើមកៅស៊ូ ខាងក្រោយរោងចក្រ ។

ដានី: គេធ្វើមេទ្ទិញធ្វើពេលដែល យូរៗម្តងឬខស្សាហ៍ធ្វើញឹកញាប់?

អៀង: ដូចថាកំណត់ខែ មួយខែ ឬមួយឆ្នាំធ្វើ មួយឆ្នាំធ្វើ២-៣ដងដែរ រាប់រយនាក់ ។

ដានី: គេធ្វើពេលមេទ្ទិញ ធ្វើប៉ុន្មានថ្ងៃទៅ?

អៀង: មួយថ្ងៃ ម៉ោង៧-១២ចប់ហើយ ។

ដានី: ពីណាគេឡើងធ្វើគណៈអធិបតី ឡើងនិយាយ?

អៀង: គណៈគេមេធំៗអីហ្នឹង យើងចាំតែស្តាប់គេ ។

ដានីៈ យើងអ្នកតូចតាចអត់បាន?

អៀងៈ អត់ទេ ។

ដានីៈ គេច្រើននិយាយពីអីពេលមេទ្ទីញ?

អៀងៈ លោកគ្រូអើយខ្ញុំមិនចាំទេ ភ្លេចអស់ហើយ មិនដឹងនិយាយពីស្អីៗ ភ្លេចអស់ហើយ ។

ដានីៈ កាលហ្នឹងមីងចេះចាំចំរៀងខាងបដិវត្តន៍ទេ?

អៀងៈ ភ្លេចអស់ខ្លះហើយ ។

ដានីៈ ចាំខ្លះដែរ?

អៀងៈ ១-២មាត់ភ្លេចអស់ហើយ ។

ដានីៈ ចាំស្អីខ្លះទៅ?

អៀងៈ ចំរៀង ។

ដានីៈ បាទ?

អៀងៈ ចាំវាមិនអស់ ១-២មាត់ ។

ដានីៈ មីងអាចសូត្រខ្ញុំចង់ស្តាប់បន្តិច គេថាម៉េចទៅ ។

អៀងៈ ចាំ១-២មាត់មិនដឹងបទម៉េច ភ្លេចអស់ហើយលោកគ្រូអើយ ឥឡូវនេះមិនចាប់អារម្មណ៍ ។ ពីដើមមិនដឹងថាម៉េចទេ នៅក្មេងៗចាំច្រើនតែឥឡូវភ្លេចអស់ហើយមិនដឹងស្អីៗទេ ពីដើមពួកខ្ញុំសុទ្ធតែអ្នកកំប្លែងដែរ នៅរោងចក្រសុទ្ធតែអ្នកខិលៗដូចគ្នា ពេលយប់ឡើងអត់ដឹងថាហត់ ថានឿយអីទេ ប្រលែងគ្នា អ្នកណារាំៗ អ្នកណាច្រៀងៗដែរហ្នឹង តែអត់សូវចាំឥឡូវនេះ ។ ខ្ញុំមិនថាម៉េចទេនៅចំការកៅស៊ូបើខ្ញុំនៅកងចល័តមិនកើតទេ រឿងហូបចុកមេកន្លែងខ្ញុំគេទូលាយគ្រាន់បើដែរ ។

ដានីៈ តាជីម គាត់ទូលាយដែរ?

អៀងៈ ចា៎! គណៈស្រុក គណៈតំបន់ ដូចថាភូមិគេទូលាយគ្រាន់បើ ពេលហូប ចុក តែកន្លែងនោះមិនខ្វះអីទេ ចេកៗ ខ្នុរៗ ពួកខ្ញុំនោះសំបូរណាស់ បើខែនេះវិញពួកខ្ញុំគេចាត់តាំងឲ្យទៅកាប់ចេក កាប់ចេកអីថ្នល់បែក ហើយទាំងឡានៗ ហើយខ្ញុំអត់សូវហត់ទេ ព្រោះហូបអីក៏មិនសូវនេះប៉ុន្មានដែរទៅនៅនោះ ខែចេកៗ ខែទៀបៗ ខែខ្នុរៗ ។

ដានីៈ សប្បាយណាស់?

អៀងៈ ចា៎! ហូបគ្រប់គ្រាន់ ។

ដានីៈ អត់ខ្លាចអីទេកាលហ្នឹង?

អៀងៈ អត់មានខ្លាចអីទេ ។

ដានី៖ អត់មានលឺថាគេចាប់?

អៀង៖ ឃើញ និយាយពីចាប់តែនឹងមុខៗឯង តែគ្មាននឹកឃើញថាខ្លាច ថារបស់អីអត់គិតទេ ខ្ញុំទៅដឹកកៅស៊ូ ទៅកាយដីរកៅស៊ូ ខ្ញុំឃើញទាំងកន្លែងគេសម្លាប់ទៀត ។

ដានី៖ នៅណា?

អៀង៖ មានអណ្តូង កន្លែងគេហៅចំការតាប៉ុមៗ អណ្តូងនោះរាប់ម៉ែត្រ ពួកខ្ញុំដើរទៅបត់ជើង អណ្តូងគេធំណាស់ហ្នឹងខ្ញុំដាក់ស្តែងហើយ តែអត់ដឹងថាខ្លាចរាប់ ខ្លាចរស់ទេ អត់ទទេសោះ

ដានី៖ អណ្តូងហ្នឹងហៅចំការតាប៉ុម?

អៀង៖ ចា៎! ចំការកៅស៊ូ ។

ដានី៖ នៅជិតកន្លែងមីងដែរ?

អៀង៖ នៅក្នុងព្រៃកៅស៊ូ ។

ដានី៖ នៅក្នុងព្រៃកៅស៊ូតែរបស់កន្លែងមីងធ្វើការហ្នឹង?

អៀង៖ កន្លែងពួកខ្ញុំជុតដីរ ។

ដានី៖ ជិតកន្លែងរបស់តាជីម ដែរអត់ទេ ឬឆ្ងាយ?

អៀង៖ ជិត ប្រហែលយើងទៅមុខ ហើយពួកខ្ញុំពេលខែនេះគេឲ្យដឹកដីរបាន ខែនេះគេឲ្យដឹកដីរមក

ដានី៖ ពេលឃើញអីចឹងភ័យទេ ឬអត់ភ័យ?

អៀង៖ ភ័យក៏មិនដឹងធ្វើយ៉ាងម៉េច ឃើញក៏យើងអត់មានមាត់ មានកអីទេ គេថាមុខសារផ្សេងៗ អ្នកណាធ្វើម៉េចធ្វើទៅ យើងប្រឹងតែធ្វើការងារ តែរឿងចាប់ រឿងចងកន្លែងខ្ញុំមិនឃើញ ពេលគេប្រជុំគេរើសអ្នកណាមួយក្បត់ គេស្រាវជ្រាវ គេនាំទៅចាប់ដាក់ឡាន មនុស្សចាប់ដាក់ឡាន ។

ដានី៖ ធំក្លិនអីដែលអត់ពេលយើងទៅជិត?

អៀង៖ មិនធំក្លិនអី យើងទៅដូចថាអណ្តូងចំងាយគេអ្នកយាម គេអ្នកចាំសម្លាប់គេនៅខាងៗ គេឲ្យយើងចូលទៅមើលអត់ទេ ។

ដានី៖ គេអត់ឲ្យយើងចូលមើលទេ?

អៀង៖ ចូលអត់បាន ។

ដានី៖ តែមីងគ្រាន់តែឃើញគេអ្នកយាម?

អៀង៖ គ្រាន់តែឃើញគេហ្នឹងឯង ។

ដានី៖ ហើយឃើញមនុស្សដែលគេទៅយកមកសម្លាប់?

អៀង៖ ហ្នឹងឯង ។

ដានីៈ មានស្រែកអត់?

អៀងៈ អត់ទេ មិនដឹងស្រែក ឬមិនស្រែក បើយើងទៅចំពេលគេ ។

ដានីៈ មីងឃើញចម្ងាយប៉ុណ្ណា?

អៀងៈ ឆ្ងាយដែរ ប្រហែល១០០-២០០ម៉ែត្រឃើញគេយាមជុំវិញ ។

ដានីៈ ពីហ្នឹងទៅដើមអំពិលទឹកបារាំង?

អៀងៈ អត់ទេឆ្ងាយណាស់ ។

ដានីៈ ពីហ្នឹងទៅផ្ទះពូ?

អៀងៈ ណ៊ាំផ្ទះឆ្ងាយ ដូចថាខ្ញុំគេឲ្យយាម តែពួកខ្ញុំមកបាត់ កុំមកអី យើងទៅវិញ តែយើងដឹងថា កន្លែងហ្នឹងចូលអត់បាន ។

ដានីៈ កន្លែងឃោឃាតគេ?

អៀងៈ ហ្នឹងឯង ។

ដានីៈ កន្លែងឃោឃាតរបស់តាដឹម?

អៀងៈ មិនដឹងជារបស់អ្នកណា ខ្ញុំអត់ដឹង យើងដើរយកជ័រវិញទៅ កើបជ័រដាក់ឡាន ។

ដានីៈ យើងរើសជ័រទៅ?

អៀងៈ កើបជ័រដាក់ឡាន យើងដឹកមកកន្លែងវិញ គេធ្វើម៉េចធ្វើទៅរឿងរបស់គេ យើងដឹងកន្លែងហ្នឹងតែមិនដឹងធ្វើម៉េច ពួកខ្ញុំឆោតណាស់ ត្បិតតែប៉ុណ្ណឹងហើយ ដឹងថាគេសម្លាប់ហើយ ក៏អត់មាននឹកឃើញ អញថ្ងៃទៅមុខងាប់អីអត់ទេ ក្មេងល្ងង់ៗ មិនដឹងចាប់អារម្មណ៍ថាខ្លួនងាប់មិនងាប់ទេ ។

ដានីៈ កាលហ្នឹងមីងអត់មានសេសសល់របស់របរប្រើប្រាស់កាលពីសម័យហ្នឹង?

អៀងៈ អត់ទេ អត់មានទេ ។

ដានីៈ ចាន, ស្លាបព្រា, ខោអាវ, ស្បែកជើង, រូបថត?

អៀងៈ បើខោអាវសំលៀកបំពាក់បាន បើអត់រូបអត់មានទេ ទទេ ។

ដានីៈ ខោអាវមាននៅសល់ដែលពីនោះមក?

អៀងៈ ខោអាវមានសល់ដែលយើងស្លៀកពាក់គេបើកឲ្យហ្នឹង ១-២កំប្លេ ១ឆ្នាំបាន២-៣កំប្លេ ។

ដានីៈ តែឥឡូវមាននៅសល់ទេ?

អៀងៈ អត់ទេ អត់មាននៅសល់ទេ អស់ហើយ អស់រលីងហើយ ។ ហើយខោអាវមានស្អី អត់មានខោអាវប្រដិបៗពណ៌ប្រផេះ ល្វរបុក បើគេសំរាប់បើកឲ្យទទួលភ្ញៀវម្តងខោអាវស ។

ដានីៈ កាលហ្នឹងមីងអាយុប៉ុន្មាន?

អឿន:	អាយុដប់ដាន ។

ដានី:	ដប់ប៉ុន្មានទៅ?

អឿន:	១៥អី ។

ដានី:	នៅក្មេងដែលនៅពេលចក្រ?

អឿន:	នៅក្មេង ១៥-១៦ ។

ដានី:	អីចឹងកាលនៅលើកដីទំនប់១ មកភា ហ្នឹងនៅតូច?

អឿន:	នៅតូចទេ ។

ដានី:	១៤-១៥ឆ្នាំ?

អឿន:	អាចខ្ញុំទៅ៧/៩អាចទៅនៅចំការកៅស៊ូអាច១៧-១៨ហើយ ព្រោះខ្ញុំនៅកងចល័ត១៥អី ហ្នឹងឯង ។

ដានី:	ពីអ្នកស្រុកភូមិទៅជាមួយគ្នាប៉ុន្មាននាក់?

អឿន:	៣នាក់ ។

ដានី:	សព្វថ្ងៃគាត់នៅដែលទេ?

អឿន:	នៅ២ស្លាប់១ ។

ដានី:	គាត់នៅណាខ្លះទៅ?

អឿន:	នៅស្រុក មកតែខ្ញុំនេះមួយ ។

ដានី:	ពីរនាក់ទៀតឈ្មោះអីទៅ?

អឿន:	មួយនោះឈ្មោះយីន មួយទៀតឈ្មោះស៊ិយ តែស៊ិយ ហ្នឹងស្លាប់បាត់ហើយ ។

ដានី:	ស៊ិយ ស្លាប់ហើយ?

អឿន:	ចា៎! នៅយីន ។

ដានី:	តែសព្វថ្ងៃគាត់នៅ?

អឿន:	នៅភូមិទំនប់រាល់ថ្ងៃ ។

ដានី:	មានតែមីងទេមកនៅនេះ?

អឿន:	ចា៎! គេរើសមួយភូមិហ្នឹងគ្នា៣នាក់ ។

ដានី:	ហើយកាលហ្នឹងពូគាត់នៅហ្នឹងដែរ?

អឿន:	ចា៎! គ្រួសារខ្ញុំនៅហ្នឹង គេធ្វើខាងយោធា ។

ដានី:	គាត់នៅជាមួយតាជីម តែម្តងអីចឹង?

អឿន:	ចា៎! នៅជាមួយអ៊ំ ផុតពីអ៊ំមកបានមកនៅជាមួយតាសូត្រ ។

ដានី៖ តាណា?

អៀង៖ តាសូត្រ ។

ដានី៖ តាសូត្រ?

អៀង៖ គ្រួសារខ្ញុំ ។

ដានី៖ តាសូត្រ ក្រោយបានមកនៅជាមួយតាពីន?

អៀង៖ ចាំ! ក្រោយមក ។

ដានី៖ តាសូត្រ គាត់ធ្វើអី?

អៀង៖ តាសូត្រ ទាហាន យោធា ។

ដានី៖ យោធានៅ?

អៀង៖ យោធានៅចំការកៅស៊ូ ដល់ពេលផ្លាស់ពីចំការកៅស៊ូគេឲ្យមកធ្វើនៅកំពង់ធំ ។

ដានី៖ មកធ្វើការនៅកំពង់ធំវិញ?

អៀង៖ ចាំ! ដល់៧៩នេះ បានគាត់នៅជាមួយតាពីន ។

ដានី៖ គ្រួសារមីងកាលហ្នឹងគាត់នៅឈ្មោះហ្នឹងដដែល ឬគាត់ប្តូរឈ្មោះ?

អៀង៖ គាត់នៅដដែលតែម៉ែគាត់ហៅតែអាង៉ា ។

ដានី៖ ហៅង៉ា?

អៀង៖ អ្នកស្រុកនោះហៅអាអ៊ិនៗ តែម៉ែគាត់ហៅអាង៉ាៗ បងប្អូនទេ ហៅអាង៉ា ។

ដានី៖ តែឈ្មោះ អ៊ិន ហ្នឹងអ្នកស្រុកអ្នកភូមិក៏ហៅអ៊ិន អីចឹងដែរ ។

អៀង៖ ចាំ!

ដានី៖ តែម្តាយហៅង៉ា?

អៀង៖ ចាំ!

ដានី៖ គាត់ទៅនៅចំការកៅស៊ូមុនមីង?

អៀង៖ គាត់ទៅមុនខ្ញុំ ចុះគេយោធានោះ ខ្ញុំទើបតែគេរើសក្រោយ គាត់ទៅយូរហើយតាំងពី៧១-៧២មិនដឹង ។

ដានី៖ តែកាលមីងនៅក្នុងចំការកៅស៊ូ ហើយកាលគាត់ធ្វើយោធា យើងជួបស្គាល់គ្នា ខស្សោហ៍និយាយគ្នា?

អៀង៖ ចាំ!

ដានី៖ ខស្សោហ៍និយាយគ្នាមកពីស្រុកភូមិជាមួយគ្នា?

អៀង៖ ចាំ!

ដានី:	ជាប់បងប្អូនគ្នាដែលអត់ទេ?

អៀង:	ជាប់អាចជីទួត បងប្អូន ខ្ញុំនិងគាត់ជាប់សាច់ឈាមដែរ តែចាស់ៗពីដើមគាត់ស្គាល់ ។

ដានី:	អីចឹងដល់ពេលមីងនៅហ្នឹងរហូតដល់យួនចូល ឆ្នាំ៧៩ ។

អៀង:	យួនមក ខ្មែរក្រហមចាញ់ មួយសារហ្នឹងអ្នកណាទៅផ្ទះក៏ទៅ អ្នកណាទៅតាមអង្គភាពក៏ទៅៗ ពួកខ្ញុំក៏គ្នា៦-៧នាក់ អ្នកបុស្សខ្មុរមកតាមពួកខ្ញុំ២នាក់ទៀត មកតាមពួកខ្ញុំមកកំពង់ធំ ។ អ្នកបុស្សខ្មុរធ្វើការជាមួយគ្នា នៅផ្ទះជាមួយគ្នា ដល់ម៉ោង៨យប់ពូៗខាងយោធាគាត់មកប្រាប់ថា ចុះគេហៅថាយួន នារីយួនមកដល់ត្រើងហើយ ពួកខ្ញុំថាមកដល់ត្រើង ខ្លះគេរត់ចូលចំការកៅស៊ូ ពួកខ្ញុំមិនរត់ចូល រត់មកមួយយប់ហ្នឹងទាល់តែដល់តាំងក្រសាំង មួយយប់គ្នា៧នាក់ ដើរផង ពេលឃើញភ្លើងឡានទាំគ្នារត់គេចពីផ្លូវចូលចំការកៅស៊ូ ពេលផុតឡានទាំគ្នាឡើងផ្លូវវិញ ដើរតាំងពីតាប្រុកមកមួយយប់ទល់ព្រឹកម៉ោង៤ដល់តាំងក្រសាំង ពួកខ្ញុំដើរមួយយប់ ។ គេរត់ចូលព្រៃ គេចូលទៅកន្លែងវិញ ពួកខ្ញុំអត់ ។

ដានី:	កាលហ្នឹងពីណាប្រកាសថាអ្នកណាចង់ទៅតាមអង្គភាពក៏ទៅ អ្នកណាចង់ទៅផ្ទះក៏ទៅ?

អៀង:	គេមេ អ្នកនៅក្តាប់កន្លែងពួកខ្ញុំ ។

ដានី:	ពីណាគេឈ្មោះអី?

អៀង:	ឈ្មោះបងរី ប្រធាននារី ។

ដានី:	បងរី?

អៀង:	ឈ្មោះរី ឥឡូវគាត់នៅលិច ។

ដានី:	នៅណា?

អៀង:	នៅលិច ។

ដានី:	នៅលិចនៅណា?

អៀង:	នៅម៉ាឡៃ បែកយូរហើយតាំងពីរត់ ខ្ញុំអត់ដែលបានជួបគាត់ ។

ដានី:	កាលហ្នឹងមានឈ្មោះ ឌុច មួយមាននៅហ្នឹងដែលអត់?

អៀង:	នៅហ្នឹង ។

ដានី:	គាត់នៅណា?

អៀង:	ពូឌុច នៅដែលខ្ញុំទៅអត់ទាន់ទេ លឺតែឈ្មោះ គាត់ក្តាប់កន្លែងហ្នឹងឯងតែខ្ញុំទៅ អត់ទាន់ទេ ឌុច ហ្នឹងគេថាក្បត់ពីដើម តាឌុចៗ គេចាប់ទៅ ពួកខ្ញុំទៅក្រោយទេ តាឌុចៗ ក្តាប់ពីដើមកន្លែងហ្នឹងដែរ តែពួកខ្ញុំទៅអត់ទាន់ទេ ។

ដានី:	អីចឹងដល់ពេលឆ្នាំ៧៩ គេប្រកាសប្រាប់អីចឹងមីងត្រឡប់ចាក់មកកំពង់ធំវិញ?

អៀង៖ ចា៎! នាំគ្នារត់មក ។

ដានី៖ ហើយអង្គភាពគេទៅណាទៅ?

អៀង៖ អង្គភាពគេបក ខ្លះគេទៅតាមកង១ គេឡានមិនដឹងដឹកយកទៅខាងណាបេះតែទៅ ពួកខ្ញុំនៅនឹងអង្គភាពដែរ ប៉ុន្តែពួកខ្ញុំមិនណា បើគេថាអ្នកណាទៅផ្ទះក៏ទៅៗ អ្នកណាទៅណាក៏ទៅៗ ពួកខ្ញុំតំរង់មកផ្ទះហ្នឹងឯង ។

ដានី៖ ប៉ុន្មានខែបានមកដល់ផ្ទះ?

អៀង៖ អត់ទេ ខ្ញុំមកពីចំការកៅស៊ូហ្នឹងឯង មិនឃើញខ្ញុំថាមួយយប់ មួយយប់មកដល់តាំងក្រសាំង ពីដើមកងចល័តគេនៅធ្វើការនឹងតាំងក្រសាំងស្គាល់ក៏ខ្ញុំមកតាមគេ មកផ្ទះខ្ញុំ ។

ដានី៖ មកតាមគេមកផ្ទះវិញ?

អៀង៖ ចា៎! មកផ្ទះ ដណ្តើរទៅ អ្នកណាតាមអង្គភាពតាមទៅ អ្នកដើរអត់អង្គភាពគេតំរង់ផ្ទះក៏មកតាមផ្លូវហែរគេនិងខ្ញុំនេះឯងគ្រប់គ្នា ។ ផ្ទះគេជិតក៏គេចូលលឿនទៅ ឯងឆ្ងាយក៏មួយយប់បេះតែមក១ មកដល់ផ្ទះហ្នឹងគេថាប្រមូលមួយសារទៀត គេថាអ្នកណានៅអង្គភាពណាគេឲ្យទៅវិញ ពួកខ្ញុំអត់ទៅ ។

ដានី៖ ពីណាគេប្រមូល?

អៀង៖ មួយសារហ្នឹងអ្នកណាទេគេបេះតែដើរប្រមូល តែពួកខ្ញុំអត់ទៅ ថាខ្ជិលទៅណាស់រត់មកដល់ផ្ទះហើយខ្ជិលទៅ ។

ដានី៖ ពេលមឹងមកដល់ផ្ទះកាលហ្នឹងពូអត់មកទេ?

អៀង៖ នៅទេ ។

ដានី៖ ពូគាត់ទៅតាមអង្គភាព?

អៀង៖ ចា៎! ទៅតាមអង្គភាព ទៅជាមួយអាំនេះឯង គេហៅថាចូលព្រៃ ។

ដានី៖ កាលហ្នឹងគាត់នៅជាប់ជាមួយតាជីម?

អៀង៖ ចា៎! រត់ចូលជាមួយរហូត ដល់គាត់ទៅនៅនោះមិនសុខ នេះមិនសុខ គេហៅថាយួនវ៉ៃ ទៅនៅស្រុកគេដឹងកន្លែងគេតាមវ៉ៃ រសាត់ត្រែងបែកគ្នា ខ្លះបានឡើងភ្នំផុតទៅ ខ្លះក៏នៅទៅ ខ្ញុំអត់បានចូលព្រៃនឹងគេទេ តែគ្រួសារខ្ញុំទេ ដល់ពេលនេះទៅបានតាពីន នេះហៅមកវិញ ។

ដានី៖ ដល់ឆ្នាំណាដែលថាគាត់ឈឺហើយគាត់មកផ្ទះ មកព្យាបាល?

អៀង៖ មិនដឹងឆ្នាំប៉ុន្មានទេកាលហ្នឹង ភ្លេចចាំ ។ អ៊ូហ៍! ស្មានតែមិនរស់ទេម្តាយឪពុកមើលអស់រាប់ដំឡឹងគាត់មួយ ឡើងកដៃ កជើងថាមិនមែនមនុស្សទេដូចស្វា ។

ដានី៖ គាត់តូចដែរ?

អៀង: គាត់តូចទៀត ស្ទិតយើងអត់មានបាយ មិនដឹងប៉ុន្មានខែអត់នោះ គាត់នៅមួយសារហ្នឹង នៅព្រៃឡង់ រួចដល់ពេលនេះទៅរត់បែកបាក់គ្នា អត់បាយ ។

ដានី: ដល់ពេលមកព្យាបាលជាបានការជាមួយមីង?

អៀង: ចាំ!

ដានី: ការឆ្នាំ៨២?

អៀង: ៨២ ការរួចហើយបានតាពីន ធ្វើការនៅកំពង់ធំគាត់ហៅមកវិញ ។

ដានី: ហៅគាត់មកវិញ?

អៀង: ហៅគាត់មកវិញខ្ញុំអត់ទាន់មកទេ ។

ដានី: បែកគ្នាអីចឹងមីងអត់ថាអីទេ? ការហើយគាត់មកអីចឹង?

អៀង: ខ្ញុំអត់មានថាអី ។

ដានី: ឬក៏ខឹងគ្នាខ្លះដែរបានគាត់មក?

អៀង: តាពីន ហៅគាត់មកក៏មកទៅ អត់មានថាអីទេខ្ញុំនៅ អ្នកស្រុកខ្ញុំធ្វើស្រែ ធ្វើចំការ ។

ដានី: តែយើងការហើយយើងជាប្ដី ប្រពន្ធ យើងបែកគ្នាអីចឹង ក្រែងអ្នកខ្លះខឹងគ្នាមួយឆាវក៏ទៅមួយសារសិន?

អៀង: អត់ទេ គ្រួសារខ្ញុំអត់មានខឹងគ្នាទេ តាពីន ហៅមកក៏គាត់មក គាត់ថាឲ្យខ្ញុំនៅផ្ទះ បើឡើងទៅភ្នំគេស្រួលបបួលគាត់យកខ្ញុំទៅភ្នំ ឡើងទៅស្រុកថៃ ។

ដានី: ប៉ុន្តែដំបូងពេលដែលគាត់ទៅ គាត់ខស្សាហ៍ចេញចូលមកលេងមីងដែរ?

អៀង: គាត់ខស្សាហ៍ចេញចូល ព្រោះខ្ញុំកាប់ចំការ ស្រុកខ្ញុំធ្វើតែចំការទេ ធ្វើអីតាត្រាវ ព្រីង ឆ្ងាយណាស់ស្រុកខ្ញុំ ដល់ពេលទៅគេហៅពួកប៉ុល ពត១ធ្វើការ ដល់ពេលនេះគ្រួសារខ្ញុំទៅទៅលើភ្នំគេស្រួល ទៅមិនបាច់នៅ ខ្ញុំមកតាម ។

ដានី: បាទ?

អៀង: ខ្ញុំមកតាមគាត់ ។

ដានី: ឆ្នាំណា?

អៀង: ឆ្នាំមើល៨៧ ខ្ញុំឡើងភ្នំ៨៧ ។

ដានី: ឆ្នាំ៨៧មីងមកតាមគាត់នៅណាទៅ?

អៀង: នោះទៅដីថៃ ។

ដានី: ទៅដីថៃគេហៅអីគេហ្នឹង?

អៀង: នៅដីថៃហ្នឹងឯង ។

ដានី៖ ប៉ុន្តែគេហៅឈ្មោះអីគេ?

អៀង៖ គេហៅក-៧ ខ្ញុំទៅនៅបាន១ខែ ។

ដានី៖ នៅបាន១ខែទេ?

អៀង៖ ចា៎! នៅបានមួយខែតាម៉ុក ឲ្យចុះមកក្រោមវិញ មកនៅ ។

ដានី៖ ឆ្នាំ៨៧យើងអាចចុះមកក្រោមបានហើយ?

អៀង៖ បាន ៨៧-៨៨ គេឲ្យហែរៗប្រជាជនចុះពីដីថៃហែរៗ ៨៧-៨៨រហូត ។

ដានី៖ អ៊ីចឹងពេលមកនៅដីថៃ មកនៅក-៧អីហើយ មីងនៅជួបជុំជាមួយពូ?

អៀង៖ ជាមួយគ្រួសារខ្ញុំ ។

ដានី៖ អត់បានបែកគ្នាទៀតទេ?

អៀង៖ អត់មានបែកគ្នាទេ ដល់ពេលមកនៅនេះបានគេឲ្យចាត់កំលាំងឲ្យទៅធ្វើការតាមខេត្ត ខាងកំពង់ធំ ទៅភ្នំរៀង ហើយយើងនៅនេះទៅ ។

ដានី៖ ដល់ពេលអ៊ីចឹង ពេលនៅក-៧បានមួយខែ ចុះមកនៅណាទៅ?

អៀង៖ នៅនោះអូរជីក ។

ដានី៖ នៅខាងអន្លង់វែងវិញ?

អៀង៖ ហ្នឹងហើយនៅខាងអន្លង់វែង អូរជីក ។

ដានី៖ នៅក្នុងកងអីទៅ?

អៀង៖ នៅកងតាពីន ។

ដានី៖ កងពលរបស់ពីណា?

អៀង៖ កងពលតា០៦ មកបាននៅកន្លែងតា០៦ ។

ដានី៖ អ៊ីចឹងកងពលតា០៦ កងពល៩២០?

អៀង៖ ចា៎!

ដានី៖ អ៊ីចឹងតាពីន កងពល៩២០ទេ?

អៀង៖ ហ្នឹងហើយ ដល់ពេលនេះបានតា០៥ គាត់នៅនេះ គាតហៅតាពីន ឲ្យមកនៅនេះ ។

ដានី៖ ម៉េចបានបែក?

អៀង៖ បំបែកតាមអង្គភាព តា០៦ គាត់នៅនោះទៅ តា០៥ គាត់នេះ ។

ដានី៖ មិនមែននៅជាមួយតាឆន ទេ?

អៀង៖ អត់ទេ ។

ដានី៖ អត់ដែលនៅជាមួយតាឆន ទេ?

អឿន: អត់ទេ ខ្ញុំអត់ដែលនៅទេ ។

ដានី: អ៊ីចឹងពេលដែលចុះមកដំបូង មកដល់ទំនប់ដាច់ នៅទំនប់ដាច់បានយូរទេ?

អឿន: ខ្ញុំចុះមកដំបូងនៅកន្លែងតា០៦ នៅអន្លង់វែង ដល់ពេលដូចថាពីដើមគេហៅថារំដោះដីបានបន្តិចៗតាមនេះ តា០៥ គាត់មកនៅនេះ ។ តា០៦ ឲ្យកងតាពីន មកនៅនេះ មកនៅជាមួយតា០៥ទៅ ។

ដានី: ដល់ពេលចេញពីកង អ៊ីចឹងតាពីន គាត់ដាច់ចេញពីតា០៦ មកនៅជាមួយតា០៥វិញ?

អឿន: ចា៎! ដាច់ពីតា០៦ មកនៅជាមួយតា០៥ ។

ដានី: ឆ្នាំណាមកនៅនេះ? យើងចុះមកនៅកន្លែងទំនប់ដាច់ឆ្នាំ៨៧-៨៨?

អឿន: ចា៎!

ដានី: នៅបានរយៈប៉ុន្មានបានមកនៅនេះវិញ?

អឿន: នៅយូរឆ្នាំដែលណា៎ នៅយូរដែរ ហើយបានឲ្យមកនៅ នៅបាន២-៣ឆ្នាំដែរ នៅកន្លែងតា០៦ នៅបាន២-៣ឆ្នាំហើយបានតា០៥ ឲ្យមកនៅជាមួយ ។

ដានី: មកនៅជាមួយតា០៥ នៅណា?

អឿន: នៅនេះឯង ។

ដានី: នៅផ្ទះហ្នឹង?

អឿន: ចា៎! នៅដីនេះឯង តា០៥នៅទំនប់ដាច់ ។

ដានី: អត់ចាំឆ្នាំដែលមីងមកនៅដំបូង?

អឿន: អត់ចាំទេ មិនដឹងឆ្នាំណាខ្ញុំអត់ចាំ ។

ដានី: ដល់៩០នៅ?

អឿន: ជំនាន់អ៊ុនគាក់ខ្ញុំនៅនោះនៅទេ ។

ដានី: ជំនាន់អ៊ុនគាក់នៅនោះនៅឡើយទេ?

អឿន: ចា៎!

ដានី: គេបោះឆ្នោតហើយនៅ?

អឿន: បោះហើយ ។

ដានី: បោះហើយបានមកនៅនេះ?

អឿន: ចា៎!

ដានី: បោះបានយូរទេ?

អឿន: បោះហើយ១-២ឆ្នាំបានគេឲ្យមកនៅនេះ ។

ដានី៖ ដល់ពេលមកនៅនេះ ។

អឿង៖ មកនៅនេះនៅអីចឹងឯងទៅ ដូចថាទាហានរដ្ឋាភិបាលមកវ៉ៃ នាំគ្នារត់ទៅកន្លែងអូរស្វាយនោះឯងវិញទៅ ។

ដានី៖ ទាហានគេមកវ៉ៃយើងរត់ទៅអូរស្វាយ?

អឿង៖ ចា៎! ដល់ពេលទាហានគេមកវ៉ៃយើងរត់ទៅកន្លែងអូរស្វាយនោះឯងវិញ នៅអូរស្វាយបាន ២ឆ្នាំ នៅបាន២ឆ្នាំហ្នឹងក៏គេហៅសមាហរណកម្ម តាម៉ុក និងតាត្រូវគ្នានឹងរដ្ឋាភិបាល ក៏ពួកខ្ញុំរត់មកនៅកន្លែងនេះឯងរហូតឥឡូវ ។

ដានី៖ មីងមានដឹងទេរឿងខាងតាម៉ុក, តាប៉ុល ពត ឈ្លោះគ្នា? បែកបាក់គ្នា?

អឿង៖ ម៉េចនឹងដឹង រឿងផ្ទៃក្នុងគេ គ្នាគេ យើងប្រជាជនមិនដឹងធ្វើម៉េច ដឹងតែគេឈ្លោះគ្នានោះឯង តែយើងមិនដឹងធ្វើម៉េចទេ ។

ដានី៖ អត់ដឹងគេឈ្លោះគ្នារឿងអីទេ?

អឿង៖ មិនដឹងគេឈ្លោះរឿងអី ខ្វះមួយសារដែលគាត់ឈ្លោះ ដែលតាសុន សេន ពីដើមគាត់នៅលិច ដល់ពេលនេះតាម៉ុក យកមកនៅប្រោក មិនសម្លាប់ល្បីអស់មួយពូជ ។

ដានី៖ ពីណាអ្នកសម្លាប់ហ្នឹង?

អឿង៖ មិនដឹងពីណាទេ ។

ដានី៖ ខាងតាម៉ុក ថាតាប៉ុល ពត អ្នកបញ្ជាឲ្យតា០៥ទៅសម្លាប់?

អឿង៖ អត់ដឹងដែរ ទល់ស្លាប់ហើយបានដឹងថាគាត់ស្លាប់ ។

ដានី៖ មីងស្គាល់តាសុន សេន ច្បាស់ទេ?

អឿង៖ ទេ លឺតែឈ្មោះទេ ។

ដានី៖ លឺតែឈ្មោះអត់ស្គាល់គាត់?

អឿង៖ អត់ដែលទេ ។

ដានី៖ ចុះតាម៉ុក?

អឿង៖ បើតាម៉ុក ហ្នឹងបានឃើញច្បាស់ ។

ដានី៖ ធ្លាប់បាននិយាយជាមួយគាត់ទេ?

អឿង៖ ចា៎! គ្រូសារខ្ញុំទៅវះភ្នែកគាត់យកផ្លែឈើទៅឲ្យ ។

ដានី៖ វះអី? វះខ្នែង?

អឿង៖ វះខ្នែង ដល់ហើយបានឃើញ ។

ដានី៖ ពោះវៀនដុះខ្នែង?

អៀង: ចា៎! ពោះវៀនដុះខ្នែង ។

ដានី: តាម៉ុក យកផ្លែឈើទៅឲ្យផ្ទាល់?

អៀង: ចា៎! គាត់ដឹកទាំងឡានយកទៅឲ្យអ្នកជំងឺ កន្លែងពេទ្យ៨០០ចាស់ ។

ដានី: ពេទ្យ៨០០កន្លែងអូរស្វាយ?

អៀង: ចា៎! ៨០០នោះ ជិតអន្លង់វែង ។

ដានី: ៨០០ចាស់នៅជិតអន្លង់វែង?

អៀង: ចា៎!

ដានី: នៅម្តុំណា?

អៀង: នៅខាងជើងអន្លង់វែង ។

ដានី: ឥឡូវគេហៅភូមិអីគេទៅឥឡូវ?

អៀង: ឥឡូវគេហៅ៨០០ចាស់ហ្នឹងឯង កន្លែងពេទ្យចាស់ ចុះមកពីភ្នំមកជិតស្រះឈូក ខាងកើតស្រះឈូក ។

ដានី: ខាងអូរអង្រែ?

អៀង: ខាងកើតអូរអង្រែទៀត អូរអង្រែទៅលិចហើយ ។

ដានី: ទៅខាងនោះវិញ?

អៀង: ៨០០មកចេះ ។

ដានី: ៨០០ជិត១០៥?

អៀង: ហ្នឹងហើយ ។

ដានី: ជិតភូមិ១០៥?

អៀង: ចា៎ ។

ដានី: ហ្នឹងភូមិ៨០០ចាស់?

អៀង: ហ្នឹងឯង៨០០ចាស់ ។

ដានី: ចុះ៨០០ថ្មីនៅណា? អូរស្វាយនេះ?

អៀង: ហ្នឹងហើយ គេផ្លាស់ពី៨០០ចាស់មកបានគេពួក៨០០ថ្មីហ្នឹងមកនៅអូរស្វាយ គេហៅ៨០០ថ្មីនោះឯង ។

ដានី: អីចឹងពូគាត់មានតួនាទីធំដែលបានតាម៉ុក គាត់ដឹកផ្លែឈើឲ្យ?

អៀង: ទេ គាត់សំរាកពេទ្យ ។

ដានី: ចុះក្រោយមកគាត់ធ្វើប្រធានអីដែរ?

អៀង៖ គាត់ក្រោយមកអត់មានធ្វើអី ក្រោយមកសមាហរណកម្ម ។

ដានី៖ អត់ទេ កាលគាត់ធ្វើទាហានជាមួយតាពីន?

អៀង៖ អត់ដឹងទេ អត់ដឹងគេធ្វើអីទេ អត់ដឹងទេ ។

ដានី៖ តាម៉ុក មនុស្សគាត់យ៉ាងម៉េចដែលបើតាមមីងស្គាល់គាត់?

អៀង៖ យ៉ាងម៉េចគាត់ អាហ្នឹងចិត្តគំនិតគាត់មិនដឹងទេ ។

ដានី៖ ចរិតឬកពារដែលយើងធ្លាប់ឃើញគាត់ ធ្លាប់និយាយជាមួយគាត់?

អៀង៖ ឃើញមានអី ត្រូវនិយាយយើងក៏និយាយទៅ ខ្ញុំឃើញនិយាយជាមួយយើងសួរថាអ្នកឯងដេកពេទ្យអីចេះចុះ ឈឺប៉ុន្មានថ្ងៃ យើងប្រាប់គាត់ថាមកប៉ុន្មានថ្ងៃ ២-៣ថ្ងៃ ហ្នឹងបើគាត់ដើរចំយើងអត្តុយកន្លែងពេទ្យ គាត់សួរថាពូឯងដេកពេទ្យប៉ុន្មានថ្ងៃហើយ យើងឆ្លើយទៅ៣-៤ថ្ងៃអីទៅ ។ ១អាទិត្យគាត់ដឹកផ្លែឈើមកឲ្យអ្នកជំងឺម្តង គាត់ហ្នឹងឯងមក ។

ដានី៖ តាម៉ុក ហ្នឹងតែម្តង?

អៀង៖ ចាំ! ហើយនិងកូនស្រីគាត់មួយ ។

ដានី៖ ដេកពេទ្យនៅ៨០០ហ្នឹង?

អៀង៖ ចាំ!

ដានី៖ កូនស្រីមួយណា?

អៀង៖ កូនស្រីគាត់ឈ្មោះ ។

ដានី៖ កូនពៅ ឬធំ?

អៀង៖ មិនដឹងកូនស្រីហ្នឹងពៅអី ។

ដានី៖ ក្មេងឬចាស់?

អៀង៖ កាលហ្នឹងគាត់នៅលីវទេ ។

ដានី៖ កូនស្រីហ្នឹងនៅលីវ?

អៀង៖ ចាំ!

ដានី៖ ឈ្មោះប្រិច?

អៀង៖ ហ្នឹងទេដឹង ។

ដានី៖ ដែលបានប្តីជនជាតិ?

អៀង៖ មិនមែនទេ បន្ទាប់ទៀត ។

ដានី៖ ឈ្មោះ គី?

អៀង៖ គី កូនគាត់ កូនប្រុសគាត់ ។

ដានី៖ ក៏ កូនប្រសារគាត់ជនជាតិភាគតិច ។

អៀង៖ ចា៎! ឃើញគាត់មកជាមួយតែ២នាក់កូនគាត់ស្រីមួយ គាត់ជិះឡានហើយប្រាប់បុគ្គលិកគេឲ្យជញ្ជូនផ្លែឈើពីឡានដាក់ទៅតាមបន្ទប់ ។

ដានី៖ ពីណាធ្វើប្រធានពេទ្យកាលហ្នឹង?

អៀង៖ ប្រធានពេទ្យឈ្មោះតាលន ។

ដានី៖ តែម្នាក់ហ្នឹងទេ?

អៀង៖ លន ហើយសាខាទៀតមិនដឹងពីណា ពីណីទេ ២-៣នាក់ ។

ដានី៖ លោកពូគាត់ពោះវៀនដុះខ្នែងដេកពេទ្យប៉ុន្មានថ្ងៃទៅបានជា? គេវះ?

អៀង៖ មួយអាទិត្យជាង ។ វះ២ដងគ្រួសារខ្ញុំ វះជំនាន់ហ្នឹងឯងម្តង ជំនាន់យើងនេះទៅជំងឺដែកម្តង

ដានី៖ វះអីគេ?

អៀង៖ ដុំគ្រួសឡើងប្រហុំណ្ណេះ ។

ដានី៖ នៅណាហ្នឹង?

អៀង៖ នៅនេះឯងដែរ ។

ដានី៖ ដុំគ្រួសនៅណា?

អៀង៖ ដុំគ្រួសនៅតំរងនោម ២ដងហើយវះគាត់ ។

ដានី៖ វះ២ដងហើយអីចឹង? ដុំគ្រួសធំ?

អៀង៖ ចា៎! ឡើងប៉ុនៗដើងធូប៣គ្រាប់ ខ្ញុំឃើញផ្ទាល់តែម្តង វះពេទ្យជំងឺដែក ។

ដានី៖ ជំងឺដែកនៅសៀមរាប?

អៀង៖ សៀមរាបយើង ពេទ្យអង្គការ ។

ដានី៖ គាត់ចុកប៉ុម៉េច?

អៀង៖ ចុកស្ទាន់តែមិនរស់លោកគ្រូ ចុកនៅផ្ទះ ពេទ្យគេនេះថាម៉ោង១២ត្រូវស្លាប់ ខ្ញុំអើយទៅតាមព្រៃស្អាកជិះឡានផង មិនដឹងងាប់ត្រឹមណាត្រឹមណី ។

ដានី៖ កាលហ្នឹងអត់ទាន់មានផ្លូវទេ?

អៀង៖ អត់ទាន់មានផ្លូវ ផ្លូវហ្នឹងថាមួយថ្ងៃវាស់ល្ងាចអត់ទាន់ដល់សៀមរាប វេទនាមួយសារហ្នឹង ។

ដានី៖ ចុកតាមផ្លូវ?

អៀង៖ ចា៎! ចុកតាមផ្លូវ ។

ដានី៖ សែនប៉ុក៏?

អៀង៖ ឡាន មានផ្លូវណាពីដើម សុទ្ធតែផ្លូវក្រវិចក្រវៀន ភក់ ជ្រាំ ។

ដានីៈ ចុះតាប៉ុល ពត, តាខៀវ សំផន មីងស្គាល់គាត់ទេ?

អៀងៈ ទេ បើប៉ុល ពត ឃើញដែលខ្ញុំនៅចំការកៅស៊ូ ដល់ពេលដែល៧៩រួចខ្ញុំអត់ដែលជួបទេ។

ដានីៈ កាលនៅចំការកៅស៊ូ តាប៉ុល ពត គាត់ធ្លាប់ទៅដែរ?

អៀងៈ គាត់ធ្លាប់ទៅ យើងធ្វើការអីចឹងគេដើរទស្សនកិច្ចមើលកន្លែងយើងធ្វើការ។

ដានីៈ ម៉េចបានដឹងថាតាប៉ុល ពត?

អៀងៈ ចុះគេប្រាប់ គេស្គាល់នោះតាប៉ុល ពត។

ដានីៈ គាត់ស្លៀកពាក់យ៉ាងម៉េចកាលនោះ?

អៀងៈ ស្លៀកពាក់ខោអាវចិន។

ដានីៈ ខោអាវចិនពណ៌អី?

អៀងៈ ពណ៌ខៀវ ជួនកាលគាត់ពាក់អាវស។

ដានីៈ ខោអីគេ?

អៀងៈ ខោប្រដេះ។

ដានីៈ តែមីងឃើញគាត់នៅចំការកៅស៊ូ គាត់ស្លៀកពាក់អី?

អៀងៈ ហ្នឹងឯងគាត់ស្លៀកពាក់អីចឹង ឃើញគាត់ចុះមក ឡានហ្នឹងគាត់ជិះ២នាក់ប្ដីប្រពន្ធគាត់ទេ ឡានគាត់មួយហ្នឹង ពេលគាត់មកភ្ញៀវផ្សេងទៅ គាត់ហ្នឹង២នាក់ប្ដីប្រពន្ធ ហើយតែកុងមួយ យើងអង្គុយចាំត្រៀមទទួលគេ គេប្រាប់ថានេះតាប៉ុល ពត។ តាសុន សេន អត់ដែលឃើញទេ។

ដានីៈ ឃើញគាត់ច្រើនដងទេ?

អៀងៈ តាប៉ុល ពត ខ្ញុំឃើញខ្ញុំនៅចំការកៅស៊ូ ពេលគាត់ទៅទស្សនកិច្ចយើងបានឃើញទៅ បើតាម៉ុក បានឃើញ, តាសុន សេន, តាខៀវ សំផន មិនដែលឃើញទេ លឺតែឈ្មោះទេ។

ដានីៈ តាប៉ុល ពតគាត់ទៅទស្សនកិច្ចម្នាក់ឯងទេ បានឃើញតែគាត់ទេ?

អៀងៈ ទៅមានភ្ញៀវ ថាមកពីណាចិន អ្នកបកប្រែមកតាមជាមួយ គេទស្សនកិច្ចមើលកន្លែងយើងធ្វើការ មើលជ័រកៅស៊ូ។

ដានីៈ បើក្រៅពីតាប៉ុល ពត អត់ស្គាល់គេ?

អៀងៈ អត់ទេ។

ដានីៈ តាប៉ុល ពតទៅអីចឹង ដូចតាពក គាត់ទៅជាមួយអត់?

អៀងៈ ចា៎! តែតាប៉ុល ពតទៅ តាពក ទៅហើយ។

ដានីៈ តាពក, តាជឹម?

អៀង៖ ហ្នឹងហើយ គាត់ខាងយោធា ។

ដានី៖ ឃើញគាត់ដើរជាមួយដែរ?

អៀង៖ ចា៎! ដើរជាមួយ ។

ដានី៖ តាជឹម កាលហ្នឹងដៃគាត់នៅល្អឬក៏?

អៀង៖ នៅល្អ ទើបតែគាត់ដាច់ត្រូវ៧៩ហ្នឹងឯង ។

ដានី៖ ម៉េចអីចឹង?

អៀង៖ អត់ដឹងម៉េច បើកាលគាត់នៅធ្វើការពីនេះគាត់នៅល្អ រួចអ៊ំ(តាជឹម)និយាយពីដើមនិយាយ
អត់សូវច្បាស់ទេ និយាយប៉ែឡាំៗដូចឥឡូវហ្នឹងដែរ និយាយអត់សូវច្បាស់ ។

ដានី៖ តាជឹម?

អៀង៖ ចា៎!

ដានី៖ គាត់និយាយអត់សូវច្បាស់?

អៀង៖ ចា៎! គាត់និយាយដូចចិន គាត់នៅសាច់ពីដើមស្អាតណាស់អ៊ំ សាច់គាត់ក្រមាំប់ៗ ។

ដានី៖ ហើយមានខស្បាហ៍ទៅលេងគាត់ដែរ?

អៀង៖ អត់ដែរទេ អត់ដែលទៅទេ បើមួយសារខ្ញុំនៅអូរស្វាយទៅរហូតនៅជិតគាត់ ដល់ឥឡូវនេះ
នៅឆ្ងាយអត់ដែលទៅទេ ។

ដានី៖ មីង-ពូរាប់អានគាត់ស្និតស្នាល?

អៀង៖ ចា៎!

ដានី៖ ឥឡូវហ្នឹងក៏អីចឹងដែរ?

អៀង៖ ឥឡូវទៅក៏អីចឹងឯង ឃើញហៅទៅ គាត់មកហូបការជួបហៅទៅ សួរសុខសប្បាយទេ
បេះបុះទៅ ពីដើមនៅជិតខស្បាហ៍ទៅណាស់ខ្ញុំនៅអូរស្វាយ គាត់នៅផ្សាវ ។

ដានី៖ គាត់ស្គាល់មីងដោយសារពូគាត់ធ្លាប់នៅជាមួយគាត់?

អៀង៖ ចា៎!

ដានី៖ ពូគាត់ខស្បាហ៍ទៅលេងគាត់ដែរ?

អៀង៖ ចា៎! ឥឡូវបើគាត់ទៅប្រជុំជួបប្រពន្ធគាត់ ខ្ញុំទេជិតមួយឆ្នាំជាងខ្ញុំអត់ដែលទៅទេ បានតែ
មកប្រជុំជួបទៅហៅទៅ បើថាទៅផ្ទះអត់ដែលទៅទេ អត់ដែលបានទៅលេង ឥឡូវកូនៗ
បានប្រពន្ធ បានប្ដីអស់ ។

ដានី៖ កូនគាត់បានប្រពន្ធ បានប្ដី?

អៀង៖ ចា៎!

ដានី៖ មីងពេលដែលគេចាប់ផ្តើមបែកបាក់គ្នា ឈ្លោះគ្នាអីចឹង មីងយល់ឃើញយ៉ាងម៉េចខាងអន្លង់វែងថាខាងប៉ុល ពត ខាងយើងត្រពាំងប្រាសាទនេះក្បត់ ហើយខាងយើងនេះថាខាងតាម៉ុកទេ វាម៉េចដែលមីងកាលហ្នឹង?

អៀង៖ មិនដឹងម៉េចមួយសារហ្នឹង ដល់គេថាសុន សេន ដល់ពេលនេះថាតាម៉ុក ចុះចូលមកខាងរដ្ឋាភិបាលមក ក៏ពួកខ្ញុំហ្នឹងបើគេមកខាងនេះ មកខាងនេះនឹងគេមក អាខ្លះគ្នាមិនទាន់ដឹងផងឡើងទៅលើភ្នំវិញ ពួកខ្ញុំមានអី ដល់ពេលអីចឹងនាំគ្នារត់មកចូលរដ្ឋាភិបាលទៅ ។

ដានី៖ រត់ពីណាមក?

អៀង៖ មកពីអូរស្មាយមកហ្នឹង រត់ៗមក ។

ដានី៖ ទាំងអស់គ្នា?

អៀង៖ មកអូរស្មាយ អ្នកណាគេទៅផ្ទះក៏ទៅ អ្នកណាគេមិនទៅក៏ដូចពួកខ្ញុំ ក៏ខ្ជិលទៅនៅនេះ ធ្វើស្រែធ្វើចំការកាប់នឹងចប ទំរាំបានគោ បានក្របីប្រើឡើងប៉ុន្មានឆ្នាំ ខ្ញុំហត់ចង់ងាប់ស្រែតាមនេះសុទ្ធតែគាស់ ។

ដានី៖ មីងគាស់បានច្រើនទេ?

អៀង៖ ចាំ! កាប់នឹងចបហ្នឹងឯង មួយឆ្នាំៗទំរាំបានរកតិតក់ៗនឹងកំលាំង ចិញ្ចឹមគោ បានទិញទ្រព្យរបស់ប្រើ ពីដើមអត់មានគោ អត់មានរទេះអីទេ មួយសារនៅខ្មែរក្រហម មានតែកំលាំងមួយថ្ងៃបាន១០ម៉ែត្រ-២០ម៉ែត្រ ។

ដានី៖ ឥឡូវមីងកាប់បានប៉ុន្មានហិចតាទៅឥឡូវ?

អៀង៖ មួយសារកាប់នឹងចបលោកគ្រូបាន១រ៉ៃមួយឆ្នាំ ទំរាំបានគោប្រើ ។

ដានី៖ លោកពូគាត់ធ្វើប្រធានភូមិតាំងពីឆ្នាំណាមក?

អៀង៖ តាំងពីសមាហរណកម្ម ។

ដានី៖ តាំងពីសមាហរណកម្មមកគាត់ធ្វើប្រធានភូមិរហូត?

អៀង៖ ធ្វើរហូតមក ធ្វើប្រធានដូចអស់គេមិនបាច់ទេមានណាស់ តែគ្រួសារខ្ញុំត្រង់ មួយសារដីឡើងថ្លៃអ្នកខ្លះមានរាប់ពាន់ រាប់លានដុល្លា តែមិនយករបស់អ្នកណាប៉ុនក្រចកទេ អ្នកឲ្យក៏ឲ្យ មិនឲ្យក៏មិនទៅទាយក១០០-២០០-៥០០ដុល្លាអីអត់មានសោះ ។

ដានី៖ កាលហ្នឹងគេលក់ដូរដីច្រើនដែរ?

អៀង៖ គេអ្នកលក់រាប់ពាន់ដុល្លា រាប់លានដុល្លា មានដោយសារដី មកស៊ីញ៉ែ ។

ដានី៖ តាមផ្លូវៗហ្នឹង?

អៀង៖ ចាំ!

ដានី៖ គេប្រុងធ្វើផ្លូវកៅស៊ូឬអត់ទេ?

អៀង៖ ខ្ញុំមិនដឹងដែរ ។

ដានី៖ គេប្រុងបើកច្រកជប់រុន?

អៀង៖ ពីមុនមកលឺគេថាបើកច្រកជប់រុន តែឥឡូវមិនដឹងម៉េច ។

ដានី៖ ដល់លឺថាបើកច្រកគេទិញដី តាមផ្លូវ?

អៀង៖ គេទិញដីតាមផ្លូវ ទៅមើលសុទ្ធតែឈ្មោះគេហៅ ពីដើមដីឡើងថ្លៃ មួយប្លង់ៗរាប់ពាន់ដុល្លា តែគ្រួសារខ្ញុំធ្វើតាំងពីសមាហរណកម្មមិនឲ្យប្រឡាក់ញើសឈាមបងប្អូនណាទេ គេឲ្យបារី១កញ្ចប់ក៏យកដែរអត់បេះទាមទារ ឯងរាប់ពាន់ដុល្លាហើយអញ៤០០-៥០០ទទេសោះហើយ ។

ដានី៖ ហើយមីងបានទៅលេងផ្ទះវិញឆ្នាំណា?

អៀង៖ ខ្ញុំទៅលេង ខ្ញុំទៅសឹងរាល់តែឆ្នាំហ្នឹង ។

ដានី៖ ទៅចង់រាល់ឆ្នាំ?

អៀង៖ ទៅលេង ទៅធ្វើបុណ្យ ទៅបង្សុកូលពេលចូលឆ្នាំ ។

ដានី៖ ភាគច្រើនចូលឆ្នាំទៅ?

អៀង៖ ភាគច្រើនចូលឆ្នាំ ។

ដានី៖ ភ្ជុំអី?

អៀង៖ ភ្ជុំអត់ទេ បានតែចូលឆ្នាំ បើភ្ជុំបានតែឲ្យលុយទៅសងខាង ម៉ែគេខាងនោះ ម៉ែខ្ញុំ កំរបានទៅដែរភ្ជុំ បើចូលឆ្នាំហ្នឹងទៅបង្សុកូលរហូត ។

ដានី៖ នៅតែជាមួយពូអត់មានកូន?

អៀង៖ អត់ មានក្មួយមួយនិងប្អូនពៅ ។

ដានី៖ នេះប្អូនពៅ?

អៀង៖ ចាំ!

ដានី៖ ក្មួយមកពីណា?

អៀង៖ ក្មួយមកពីស្រុក ។

ដានី៖ មកពីខាងកំពង់ធំមកនៅជាមួយ?

អៀង៖ ចាំ!

ដានី៖ នៅជាមួយយូរហើយឬទើបតែមកនៅ?

អៀង៖ នៅយូរហើយតាំងពី៥ឆ្នាំ ។

ដានី៖ តាំងពីអាយុ៥ឆ្នាំ?

អៀង៖ ចាំ!

ដានី៖ ឥឡូវពេញកំលោះហើយ?

អៀង៖ ពេញកំលោះហើយ ។

ដានី៖ វែកទឹកឲ្យមីងម៉ិញហ្នឹងក្មួយ?

អៀង៖ ហ្នឹងហើយ ហ្នឹងក្មួយ នេះប្អូនខ្ញុំស្រីៗគេការ ។

ដានី៖ គេធ្លាប់មកនៅហ្នឹងដែរ?

អៀង៖ នៅខ្ញុំការឲ្យហួត ការមីនេះ ហើយមីមួយនៅត្បូងនោះ អានេះខ្ញុំទើបតែការឲ្យ ។

ដានី៖ មានប្រពន្ធហើយអីចឹង?

អៀង៖ មានហើយតែអត់នៅជុំគ្នា ។

ដានី៖ បែកគ្នាវិញ?

អៀង៖ បែកគ្នា ការរួចគេអត់ចេះនៅនេះស្រុកខ្ញុំនោះវិញ ។

ដានី៖ ពីណាគេខាងប្រពន្ធ?

អៀង៖ ប្រពន្ធអ្នកអង្គរជុំហ្នឹង ។

ដានី៖ អង្គរជុំនៅខេត្តសៀមរាបហ្នឹង?

អៀង៖ ចាំ!

ដានី៖ ពីណាអត់ចេះនៅនេះ?

អៀង៖ ប្រពន្ធអាហ្នឹង អត់ចេះនៅនេះ ទៅនៅនឹងម៉ែខ្ញុំនោះ មិនមែនទៅនៅម្តាយឯណា ។

ដានី៖ ទៅនៅកំពង់ធំ?

អៀង៖ ចាំ! នៅខាងកំពង់ធំនោះវិញ ។

ដានី៖ ឥឡូវហ្នឹង?

អៀង៖ ចាំ! ឥឡូវហ្នឹងឯង ។

ដានី៖ ប៉ុន្តែម៉េចបានអីចឹង?

អៀង៖ មិនដឹងម៉េចទេ ។

ដានី៖ មានកូន មានចៅ?

អៀង៖ កូនមួយ កូនទើបតែបានមួយខែ ។

ដានី៖ ប្តីនៅនេះ?

អៀង៖ ប្តីនៅនេះ ប្រពន្ធនៅនោះ ។

ដានី៖ ម៉េចបានអីចឹងនៅបែកគ្នា?

អៀង៖ មិនដឹងម៉េចទេ ។

ដានី៖ ប្តីទៅលេងដែរ?

អៀង៖ អត់ទេ អត់ដែលទៅទេ ។

ដានី៖ ខានទៅពីអង្កាល់?

អៀង៖ តាំងពីចូលឆ្នាំ ឆ្នាំទៅ ចូលឆ្នាំការហើយ ចូលឆ្នាំខ្ញុំទៅធ្វើបុណ្យពុកខ្ញុំ ដល់ធ្វើបុណ្យពុកខ្ញុំហ្នឹង គេនៅរួចមួយរដូវចូលឆ្នាំ ដល់ហើយអានេះមក អានេះហៅមកដែរតែគេថាអត់មក ក៏ប្អូនខ្ញុំមកតែឯង ឯប្រពន្ធនៅម៉ែខ្ញុំនោះទៅ មិនដឹងយ៉ាងម៉េច ។

ដានី៖ ដែលទាក់ទងគ្នានិយាយទូរស័ព្ទជាមួយគ្នា?

អៀង៖ អត់ទេ ។

ដានី៖ ឈ្មោះគ្នាអីចឹង?

អៀង៖ ខឹងប្រពន្ធអត់មក ទូរស័ព្ទអត់ទាក់ទង សំរាលតែម៉ែខ្ញុំ ប្អូនខ្ញុំ ឲ្យវាទៅក៏វាមិនទៅ វាថាទៅធ្វើអី បើគេមិនមកហើយ មកការរួចអស់ប្រាក់រាប់ពាន់ នឹកឃើញថាវាមករស់នៅជាមួយយើងឡើង៨-៥ឆ្នាំហើយ អាចថាគេស្រណាំនឹកឃើញថាខ្ញុំគ្មានកូនចៅ យកមកនៅជាមួយ វាថាអត់បេះនៅ ទៅនៅនឹងម៉ែខ្ញុំដដែលៗ មិនទៅនៅម៉ែឪវាណា ។

ដានី៖ ម៉េចអត់បេះនៅ អផ្សុក?

អៀង៖ មិនដឹងម៉េចទេ ។

ដានី៖ ទៅនៅនោះមនុស្សច្រើនជាងម៉េច?

អៀង៖ អត់ទេ មានណា ម៉ែខ្ញុំខ្វះខាតសឹងអី ។

ដានី៖ តែខាងនោះវាអ៊ូរអរជាងយើង?

អៀង៖ អត់ទេ អ្នកស្រែ អ្នកចំការដូចតែគ្នាបេះឯង តែមិនដឹងម៉េចគេ ។

ដានី៖ មីងធ្លាប់រស់នៅតាំងពីយើងតស៊ូ តាំងពីជំនាន់៣ឆ្នាំ សម័យយើងតស៊ូ រហូតមកសមាហរណកម្មនេះវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ ទាក់ទងពីការរស់នៅ? ទាក់ទងពីជីវភាព? ទាក់ទងពីសេរីភាព ខុសគ្នាម៉េចខ្លះទៅ?

អៀង៖ ខុសគ្នាហ្នឹងឯង រស់នៅរាល់ថ្ងៃវាធូរធារនឹងយើង ជីវភាពរស់នៅរបស់យើងវាទូលាយ យើងប្រឹងរក ប្រឹងធ្វើក៏វាធូរធាររបស់យើង វាខុសប្លែកពីយើងនៅជំនាន់ប៉ុល ពត មកបច្ចុប្បន្ននេះវាមានអី រាល់ថ្ងៃនេះយើងធ្វើការផ្សារបិញ្ចឹមក្នុងក្រុមគ្រួសារយើង កុំឲ្យតែ

យើងទៅប៉ះគេ ប៉ះឯង គ្រាន់តែធ្វើការចិញ្ចឹមជីវិតយើងអត់មានលំបាកអីទេខ្ញុំ វាធូរទូលាយស្រួល ជីវភាពក៏មិនទៅ អត់ទេ ។

ដានី: បើពីមុនមក? កាលជំនាន់យើងតស៊ូ?

អៀង: មុនមកវាលំបាក វាខ្វះខាត ហើយយើងក៏មិនបានរកស៊ីអីទូលាយដូចចេះ យើងធ្វើស្រែសំរាប់ចិញ្ចឹមជីវិតយើងតក់ៗ អត់បានថាយើងទៅរកនេះក៏បាន យើងដើរទៅណាជីវភាពយើងទូលាយ សំខាន់ឲ្យតែយើងមានលុយឥឡូវនេះ ការរស់នៅរាល់ថ្ងៃគ្មានលំបាកអីទេខ្ញុំបានរាល់ថ្ងៃបានប៉ុណ្ណេះខ្ញុំអរគុណហើយ មិនចង់ទៅប៉ុណ្ណាទៀតទេ សប្បាយក៏ពេញចិត្តពេញថ្លើមនឹងជីវិតដែលយើងរករាល់ថ្ងៃនេះ គ្មានសតិអារម្មណ៍ទៅណាទៀតទេ ។ ធ្វើទៅរកទៅ ស្រេចតែចិត្តយើង ចង់ធ្វើអីក៏បាន រកអីក៏បាន ។

ដានី: ទាក់ទងពីការដូចទំនៀមទំលាប់ប្រពៃណីកាលពីមុនជំនាន់៣ឆ្នាំ ជំនាន់យើងតស៊ូ សម័យយើងផ្តាច់ខ្លួន យើងចូលជាមួយរាជរដ្ឋាភិបាលហើយ យ៉ាងម៉េចដែរ?

អៀង: ខុសគ្នាឆ្ងាយណាស់មកសង្គមឥឡូវ ដូចខ្ញុំថាអីចឹង វាធូរធារ ។

ដានី: ពីមុនមកដូចថាយើងធ្វើបុណ្យទានយ៉ាងម៉េចដែរ?

អៀង: មិនដែលទេ បុណ្យទានយើងមិនដែលស្គាល់វត្តទេ ទើបនេះទេ នេះបុណ្យទៅណាក៏បានស្រេចតែចិត្តយើង ពីដើមមិនដែលស្គាល់វត្ត ស្គាល់លោកយ៉ាងម៉េច ទៅណាមិនដែលឃើញ យើងនៅដូចថាវាស់ដីដើរពីដើម ។

ដានី: ពីដើមវាស់ដីឲ្យដើរ?

អៀង: ចា៎! ដល់ឥឡូវមានស្អីទៀត សង្គមគេឥឡូវនេះទូលាយ យើងដើរទៅណាកុំឲ្យតែជាន់គេប៉ុណ្ណឹង ដើរបុណ្យទាន ទៅស្រុកស្រែយើងស្រេចចិត្ត ។

ដានី: នៅស្រុកភូមិយើងមានដូចថាគេ យើងមានសេរីភាពអីចឹង មានអ្នកដែលគេជឿលើសាសនាផ្សេងៗ មានដែលអត់?

អៀង: ទេ ស្រុកខ្ញុំអត់សោះ ។

ដានី: មានអីគេ?

អៀង: ទៅពីសាសនាយើង បើថាខាងយេស៊ូមិនដែលទេខ្ញុំ ។

ដានី: មានតែខាងសាសនា?

អៀង: មានតែខាងសាសនាខ្មែរយើង ។

ដានី: ព្រះពុទ្ធសាសនា?

អៀង: បើថាទៅណាៗអត់ទេ អត់មាន បើដូចគេមានសាសនាយេស៊ូ ម៉ុំនេះអត់ទេ អត់ឃើញមានៗ

ដានី: ខាងណាមានសាសនាយេស៊ូ?

អៀង: នៅខាងកំពង់ធំៗ

ដានី: ខាងស្រុកកំណើតមីង?

អៀង: ចាំ!

ដានី: នេះអត់ទេ?

អៀង: អត់ទេៗ

ដានី: ចុះសេរីភាពខាងជឿជាក់អ្នកខ្លះគេកាន់បក្សនយោបាយ មានដែល?

អៀង: មាន ប៉ុន្តែគេទៅក៏ទៅៗ យើងនៅក៏នៅ មានចិត្តរៀងខ្លួនៗ

ដានី: មានច្រើនដែលនេះ? ខាងបងប្អូនយើងដែលផ្លាច់ខ្លួនមក?

អៀង: មិនសូវប៉ុន្មានទេ ច្រើនតែអ្នកពីខាងក្នុង ដូចថាពួកខ្ញុំចាស់ៗកំរណាស់ អត់សូវទេភូមិខ្ញុំៗ

ដានី: អ្នកខាងក្នុងមក គេមកកាន់គណបក្សប្រឆាំង?

អៀង: គណបក្សប្រឆាំង គេទៅខាងណាក៏កាន់ទៅស្រេចតែចិត្តៗ

ដានី: ហើយបញ្ហាទាក់ទងនឹងដីធ្លីវិញ មានបញ្ហាអត់? ទាក់ទងប្រជាជននិងក្រុមហ៊ុន ឬបញ្ហាប្រជាជននិងប្រជាជនអី?

អៀង: ខាងខ្ញុំនេះអត់ទេ ខ្លាចតែខាងគេ ខាងគេផ្សេងៗ ភូមិគេ តែចំពោះថាភូមិខ្ញុំវាអត់ទាន់ឃើញមានទេ គ្រាន់តែថាជម្លោះគ្នាតិចតួច ព្រំភ្លឺតិចតួច រឿងក្រុមហ៊ុនពួកខ្ញុំអត់ដែលទេ អត់ទាន់ឃើញទេៗ

ដានី: ចុះមីង ក្មួយៗក្រោយៗនេះ មីងធ្លាប់និយាយរឿងរ៉ាវប្រវត្តិកាលពីជំនាន់តស៊ូលើកទំនប់ធ្វើការរោងចក្រ ឬឡើងភ្នំ ដើរកាត់ព្រៃ ឬសម័យមុនមិនទាន់ផ្ដាច់ខ្លួន មានដែលនិយាយប្រាប់ក្មេងៗដែរ?

អៀង: និយាយ ប៉ះត្រង់ណាក៏និយាយប្រាប់ ខ្លះក៏ជឿ ខ្លះថាយើងភរវ៉ា ខ្លះយើងនិយាយប្រវត្តិថា ពួកឯងនេះស្រួលមហាស្រួលហើយ បើអញពីដើមដូចថាទាហានរដ្ឋាភិបាលមកវ៉ៃ ពរកូនផង ស្ពាយអង្ករផង រត់លូនតែនឹងស្មារ ពួកឯងនេះរត់ទៅណា បើថាថៃមកសុទ្ធតែគោយន្តឯងថាលំបាកអីទៀតៗ

ដានី: ក្មួយៗថា?

អៀង: អាងតែគេមិនដឹងចេះតែភរគេហើយ ខ្លះវាថាអីចឹងទៅ ខ្លះក៏បើប្រវត្តិម៉ែឪ និយាយប្រាប់ មិនដឹងគាត់លំបាកវេទនាយ៉ាងណា ពរកូនដង ឆ្នាំង ចាន ខោអាវ សំភារៈនៅលើខ្លួនទាំងអស់ អត់មានរទេះ អត់មានគោយន្តអីណាបើបរដូចយើងរាល់ថ្ងៃ រត់លូន ខ្លះក៏ជឿទៅ ខ្លះវាថាគ្មានទេ ជិនាន់ប៉ុល ពត អ្នកណាលើកដី ៗ ពួកឯងអត់ទាន់ប្រទះ អញម៉ោង៤ឡើង ដួងម៉ឺង១ បើអ្នកណាមិនងើបទៅដើរគោះដើងតាមកន្លែងដេកហើយ ងើបឡើងកាន់បង្គីទៅ អំរែកមួយៗម្នាក់ទៅកន្លែងដី លើកទៅ ដល់ក្មេងៗឥឡូវស្រួលណាស់ម៉េចទៀត សប្បាយ តែក្មេងឥឡូវវាសប្បាយមិនដូចពីដើមដែលទេ បើវាទៅណា ទៅលេងវត្តវាអត់សូវត្រូវគ្នា ដូចគេពីដើម គេពីដើមមិនចេះឈ្លោះគ្នា វាឥឡូវមិនបានទេអាក្មេងទំនើង ឥឡូវខ្លះចូលវត្ត វាវ៉ៃគ្នាកន្លែងវត្តហ្នឹងឯង ។

ដានី: វ៉ៃនៅណា? វត្តណា?

អៀង: វត្តទំនប់ដាច់ ។

ដានី: វ៉ៃគ្នាដែរ?

អៀង: ចា៎! ដល់អីចឹងលេងម៉េចសប្បាយ ។

ដានី: ក្មេងៗកូនអ្នកស្រុកភូមិយើងធម្មតាហ្នឹង?

អៀង: ហ្នឹងឯងអ្នកស្រុកអ្នកភូមិយើងធម្មតា ឥឡូវសម័យគេជឿនលឿន ផឹកស៊ី មិនដូចក្មេងពីដើមគេអត់ ទៅវាំភូមិណាក៏ដោយ អីណាមកដុំវិញទំនប់ដាច់មិនចេះវ៉ៃគ្នា ឥឡូវអត់ទេប៉ះ តែគ្នាតិចមិនបានទេ ដេញគ្នាដូចគោហ្វូង ។

ដានី: ក្មួយៗមីងមានទៅរៀនដែលអត់?

អៀង: ក្មួយខ្ញុំអាតូចៗ?

ដានី: បាទ!

អៀង: ទៅ ។

ដានី: ទៅរៀននៅសាលាណា?

អៀង: សាលានៅទំនប់ដាច់ វត្ត ។

ដានី: ក្មួយធំបានរៀនដល់ណា?

អៀង: អាក្មួយកំលោះអត់ទេ រៀនពីតូចឥឡូវឈប់រៀន ។

ដានី: មីងនិយាយមិញខ្ញុំចាប់អារម្មណ៍ដែរ ទាក់ទងរឿងអត់ជឿ យើងនិយាយទៅថាយើងភរ ហើយទើបតែថ្មីៗដែរ ទើបតែផ្តាច់ខ្លួនថ្មីៗដែរ ទើបតែ៤-១០ឆ្នាំនេះហ្នឹង ១០ឆ្នាំជាង ចុះទំរាំតែ២០ឆ្នាំក្រោយទៀតរិតតែលែងជឿ កន្លែងនេះសុទ្ធតែព្រៃ កន្លែងនេះអត់មានផ្ទះ

ក្មេងៗប្រហែលជាមិនជឿទេ ។ អីចឹងតាមចិត្តមីង មីងគិតថាគួរតែដូចពួកខ្ញុំមកជួបមីងនេះ យើងមកសម្ភាសន៍ដើម្បីសរសេរប្រវត្តិសាស្ត្រពីភូមិ ស្រុកដែលមីងធ្លាប់នៅលើភ្នំតស៊ូ ក្រោយមកចុះមក មានសង្គ្រាមរត់ផ្លាស់ពីកន្លែងនេះ ទៅកន្លែងនោះ ស្លាយកូន ស្លាយចៅ ស្លាយអន្តរ មីងគាំទ្រឲ្យដូចថាគួរតែនៅតាមសាលា ជាពិសេសនៅត្រពាំងប្រាសាទយើង នៅអន្លង់វែង គួរតែបង្រៀនឲ្យក្មេងៗ កូនចៅជំនាន់ក្រោយបានដឹងពីប្រវត្តិចាស់ៗដូចមីង ដូចពូ អ៊ំផ្សេងៗទៀតដែលបានឆ្លងកាត់ ដើម្បីឲ្យកូនៗបានដឹង បានលឺដែលអត់? គាំទ្រឲ្យបង្រៀនតាមសាលាដែលអត់ទាក់ទងពីប្រវត្តិដូចមីង?

អៀង: មិនដឹងម៉េច បង្រៀនឲ្យវាដឹងប្រវត្តិចាស់ពីដើមចេះចុះអី ។

ដានី: បាទ! គួរតែបង្រៀនដែរ?

អៀង: បង្រៀនបាន ព្រោះប្រវត្តិវាជួរចត់ចាស់ៗ លំបាកវេទនាសព្វគ្រប់បែបយ៉ាង ហាលភ្លៀង ហាលថ្ងៃ សព្វគ្រប់ ។

ដានី: មួយទៀតចាប់ពីជំនាន់៣ឆ្នាំ កាលមីងនៅលើទំនប់ ជីកប្រឡាយ ធ្វើការនៅរោងចក្រ មីងជឿថាកាលហ្នឹងមានការប្រជាជនអីលំបាកវេទនា ហូបចុកមិនសូវឆ្អែត ហើយមានការចាប់ សម្លាប់អីចឹងដែរ ឬអត់ទេ?

អៀង: មាន! រឿងឲ្យជឿ ចិត្តខ្ញុំដែលជឿ?

ដានី: បាទ!

អៀង: យើងជឿតែយើងមិនដឹងធ្វើម៉េច យើងឃើញៗហើយតែយើងមិនដឹងធ្វើម៉េច ដូចចាស់ៗគាត់ឲ្យដាំដើមគរ ទោះបីអ្នកណាធ្វើម៉េចក៏ធ្វើទៅ ឲ្យរស់មួយខ្លួនៗអ្នកណាធ្វើម៉េចធ្វើទៅ ។ ដូចខ្ញុំនិយាយថាទៅរោងចក្រចំការកៅស៊ូឃើញគេធ្វើ យើងទៅធ្វើម៉េច យើងដើរផ្លូវផ្សេង គេផ្លូវផ្សេងទៅ យើងសំរាប់តែខ្លួនយើងរស់ទៅមុខទៀត យើងបិទភ្នែក បិទច្រមុះ ដាំដើមគរ ដើមត្នោត ។

ដានី: ដូចមីងឃើញនៅចំការតាប៉ុម ចំការកៅស៊ូហ្នឹង ។

អៀង: ហ្នឹងហើយ ។

ដានី: ឃើញយោធាសម្លាប់តែគេទៅ យើងចៀសទៅ?

អៀង: យើងចៀសទៅ យើងធ្វើការទៅ យើងឃើញគេចាប់មិនដឹងធ្វើម៉េច នៅទីងកង ទីងអគ្គភាពហ្នឹង ល្ងាចនេះគេត្រូវថាយើងដឹងហើយ ដូចខ្ញុំមេកង ដូចថារោងបាយគ្នាដាំបាយទៅមានពួកខ្ញុំពុលឡើងមួយថ្ងៃ ពុលសៀង ហ្នឹងគេថាអ្នកកន្លែងដាំបាយគេពុលសៀងដល់នេះមានឈ្មោះឌី, សឿន កន្លែងគេឲ្យដាំបាយគេចាប់យកបងឌី, បងសឿន យកទៅ

បាត់ទៅក៏យើងមិនដឹងធ្វើម៉េច ។ ដល់ក្រោយមកគេថាយើងពុលសៀង ពួកនេះឯងក្បត់ ដើម្បីថាឲ្យយើងងាប់ទាំងអស់គ្នា តែយើងវាមិនងាប់ គេជួយសង្គ្រោះទាន់ទៅដឹកទៅពេទ្យ អ្នកណាល្មមគេឲ្យហូបស្ករទៅ អ្នកណាខ្លាំងគេយកទៅពេទ្យ នៅចំការអណ្ដូងហ្នឹង ពុលសៀងឡើងចង់ងាប់ម្នាក់ៗ ។

ដានី: ដល់ពេលពុលអីចឹងគេចាប់អ្នកធ្វើចុងភៅ?

អៀង: ចា៎! ដល់ពេលពុលគេចាប់ទៅ ។

ដានី: គេចាប់ទៅកន្លែង?

អៀង: មិនដឹងគេចាប់យកទៅណា ។

ដានី: មិនមែនចាប់យកទៅកន្លែងចំការគាប៉ុម ទេ?

អៀង: អត់ទេ មិនដឹងយកទៅណា យកទៅបាត់ ដល់ពេលយើងដឹងបងឌី, បងសឿន គេយកទៅបាត់ហើយ ចេះចុះយើងដឹងព្រោះយើងនៅជាមួយគាត់ ថាមេក្បត់ ដឹងថាមេក្បត់ហើយ ខ្លាចគេរកខ្សែរយៈអីទៀតៗទៅ ប្រឹង អត់ធ្មត់ឲ្យវាផុត ។

ដានី: អីចឹងកាលមីងនៅចំការកៅស៊ូឃើញច្រើនដែរ?

អៀង: ឃើញ ។

ដានី: បើកាលនៅលើកទំនប់១ មករា អីមានឃើញអីចឹងទេ?

អៀង: បើលើកទំនប់១ មករា អត់ដែលឃើញទេ ហើយក៏អត់ទាន់ឃើញថាក្បត់យ៉ាងម៉េចៗអត់ទេ ទើបតែខ្ញុំទៅចំការកៅស៊ូបានឃើញ នៅរោងចក្រ ប៉ះណាតូៗជួសជុលហ្នឹងទៅ មានមេក្បត់គេស្រាវជ្រាវមួយៗទៀត ៤-៥នាក់ឃើញគេចាប់ទៅ ឲ្យឡើងឡានក៏មិនដឹងទៅណាបាត់ ចង់ជួយក៏មិនដឹងធ្វើម៉េច គេចាប់ទៅក៏ទៅ ។

ដានី: ខ្ញុំដូចជាអស់សំនួរអីត្រូវសួរមីងទៀតហើយ មីងមានអីចង់បញ្ជាក់បន្ថែមអ្វីដែលខ្ញុំអត់បានសួរនាំមីងទេ ។

អៀង: អស់ហើយ ។

ដានី: អីចឹងមីងភូមិនេះគេហៅភូមិអី?

អៀង: ទួលប្រាសាទ ។

ដានី: ហ្នឹងឃុំ?

អៀង: ឃុំទំនប់ដាច់ ។

ដានី: ភូមិទួលប្រាសាទ?

អៀង: ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

ដានី៖ អីចឹងខ្ញុំអរគុណមីងច្រើនដែលចំណាយពេលឲ្យខ្ញុំសាកសួរនាំពីជីវិត ពីប្រវត្តិមីងតាំងពីក្មេងរហូតដល់សព្វថ្ងៃនេះ ខ្ញុំអរគុណមីងច្រើន។

**ចប់**